# លោកនីតិ

សំរាប់ថ្នាក់

មធ្យមដ្ឋានទី ១

...មដ្ឋានទី ២

...ត្តមដ្ឋាន

ចងក្រងដោយ

គ្រូមួយក្រុម

- មេរៀន
- សំនួរ
- បរិយាយ

...គារ

សេង.ងួន.ហ៊ួ

ROYAUME DU CAMBODGE
REGIE DU DEPOT LEGAL

B-15
D-34
N. 637

161

# លោកនីតិ

ដោយ

ក្រឹម្វយ ក្រាម

សំរាប់ថ្នាក់

មធ្យមដ្ឋាន - ឧត្តមដ្ឋាន

ការផ្សាយរបស់

បណ្ណាគារ

លេខ ៦៣ វិថីព្រះបាទបិត្តុរាជា ភ្នំពេញ

រក្សាសិទ្ធិ

ព.ស. ២៥០៣ គ.ស. ១៩៦០

បណ្ណាល័យជាតិ

# យោបល់ដើម

ដោយយល់ថា «លោកនីតិ» ជាវិជ្ជាពិសេសមួយសំរាប់ណែនាំអ្នកសិក្សា ឲ្យយល់ច្បាស់ពីកិច្ចការរាជការគ្រប់គ្រងប្រទេស និងការកិច្ចរបស់អ្នករាជការ និងរបស់ប្រជារាស្ត្រខ្មែរ, យើងទាំងអស់គ្នាដែលធ្លាប់បានបំពេញមុខងារជាគ្រូបង្រៀននៅក្នុងសាលាបឋមសិក្សា គឺធ្លាប់បង្ហាត់បង្រៀនសិស្សនូវមុខវិជ្ជានេះជារឿយ ៗ មកហើយ ក៏នាំគ្នាប្រមែប្រមូលឯកសារផ្សំគំនិតគ្នា រៀបរៀងបានជាកូនសៀវភៅនេះឡើង ។

ពិតមែនហើយ តែក្នុងនេះ នៅមិនទាន់មានក្បួនខ្នាតជ្រាលជ្រៅប៉ុន្មាន ឲ្យពេញជាក្បួនខ្នាតលោកនីតិ ក៏ពិតមែន, ព្រោះយើងខ្ញុំសរសេរតម្រូវទៅតាមសមត្ថភាពនៃសិស្ស នៅបឋមសិក្សា ហើយដែលមានពេលតិចតួចស្តួចស្តើងសំរាប់សិក្សាវិជ្ជានេះ, តែយើងខ្ញុំនៅមានសង្ឃឹមជានិច្ចថា កូនសៀវ-ភៅនេះ ពិតជានឹងបានជួយសំរាលទុក្ខខ្វះក្នុងការខ្វះខាតសំភារៈ

សិក្សា នឹងជួយបំភ្លឺផ្លូវខ្លះដល់អ្នករៀនសូត្រជាពុំខាន ។ ហេតុនេះនឹងចាត់ទុកកូនសៀវភៅនេះជាជំនួយស្មារតីមួយក៏បាន ឬជាមិត្តជិតស្និទ្ធមួយដែលអាចជួយផ្តល់យោបល់ដល់អ្នកត្រូវការ រាល់ៗ ពេលក៏បាន ។

អាស្រ័យយោបល់ដូចបានពោលបញ្ជាក់ខាងលើនេះហើយ ទើបយើងខ្ញុំស្រុះស្រួលគ្នាបញ្ជានសំណៅសៀវភៅនេះ ឲ្យឡើងកាន់អក្សរពុម្ព ដើម្បីឲ្យបានហិតប្រយោជន៍ទូទៅ ។

ភ្នំពេញ ថ្ងៃទី ១៥ មេសា ១៩៦០

អ្នកនិពន្ធ

# អំពីភូមិ និងឃុំ

កន្លែងដែលមានប្រជុំផ្ទះរបស់អ្នកស្រុកច្រើនគ្នា គេហៅភូមិ ។ ភូមិនេះមានទំហំមិនស្មើគ្នាទេ អាស្រ័យលើការចូលចិត្តរបស់អ្នករស់នៅក្នុងទីនោះ គឺភូមិខ្លះក៏មានផ្ទះសម្បែង និងមនុស្សរស់នៅច្រើន ឯខ្លះទៀតមានផ្ទះតូច ៗ មនុស្សក៏តិចៗ ការគ្រប់គ្រងរបស់ភូមិនីមួយ ៗ ត្រូវមានមេភូមិម្នាក់ទទួលភារៈទាក់ទងកិច្ចការជាមួយរាជការ ។

ភូមិទាំងនោះទោះតិចច្រើនរួមគ្នាជាមួយចំណោមធំឡើងទៀត គេហៅថាឃុំ ។ មានមេឃុំម្នាក់ជាដំណាងរាជការ សំ-រាប់ប្រាស្រ័យកិច្ចការផ្ទាល់ជាមួយបណ្ដាស្រុក ។ ភ្នាក់ងារឃុំទទួលការតាក់តាំងដោយជ្រើសរើសក្នុងបណ្ដាមនុស្សចំណុះឃុំនីមួយ ៗ ហើយមានប្រធានម្នាក់ងារជាមេឃុំ ។ ក្រៅពីនេះមានសមាជិកច្រើននាក់ទៀត សំរាប់ជាជំនួយការងាររាជការឃុំ គឺមានស្មៀន ១ នាក់ ឬ ២ នាក់ , ជំទប់ ៣ ឬ ៤ នាក់ និងមេភូមិជាច្រើនរូបទៀត ។

មន្ត្រីឃុំមានមុខងារជាដំណាងក្រសួងកិច្ចការគ្រប់ក្រុមនឹង មានភារៈថែរក្សាសេចក្តីសុខក្នុងឃុំ នឹងចាត់វិធានការបង្កើនផលិតផលក្នុងស្រុក ឬ រក្សានូវសម្បត្តិសាធារណៈផ្សេងៗមានព្រៃឈើ, ផ្លូវថ្នល់, ស្ពាន, ព្រែកជាដើម ៗ មុខងារជាពិសេសរបស់មន្ត្រីឃុំមួយផ្នែកទៀត គឺខាងការចារប្រាក់ពន្ធដារពីមណ្ឌលស្រុកចំណុះឃុំ យកទៅបញ្ចូលក្នុងឃ្លាំងកិច្ចការផែនដី ៗ ក្រៅពីនេះមេឃុំមាននាទីជាមន្ត្រីអត្រានុកូលដ្ឋាន គឺជាអ្នកកាន់បញ្ជីចំនួនមនុស្សកើត-ស្លាប់ ឲ្យដឹងចំនួនពិតប្រាកដ ឬ បញ្ជីជាតិកំណើត, អាពាហ៍ពិពាហ៍ នឹងមរណភាព ៗ

អាស្រ័យដោយប្រទេសយើងនិយមលទ្ធិប្រជាធិបតេយ្យពិតប្រាកដ គឺតាំងពីសង្គមរាស្ត្រនិយម ដែលមានសម្តេចព្រះឧបយុរាជ ជាប្រធាន បានឡើងកាន់អំណាច ការជ្រើសរើសមេឃុំ ត្រូវធ្វើដោយវិធីបោះឆ្នោតសម្ងាត់ ដើម្បីយកការតែងតាំងតាមមតិភាគច្រើនរបស់បណ្តាស្រុកក្នុងឃុំ ៗ

## សំណួរ

ដូចម្ដេចហៅថាភូមិ ? ភូមិប្រជុំគ្នាកើតបានជាអ្វី? មន្ត្រីឃុំមាននរណាខ្លះ? មន្ត្រីឃុំមានមុខងារធ្វើអ្វីខ្លះ ? អ្វីហៅថាសម្បត្តិសាធារណៈ ? មានអ្វីខ្លះ? ការរើសមេឃុំត្រូវធ្វើដូចម្ដេច ? ការជ្រើសរើសបែបនេះមានតាំងពីពេលណាមក ?

# អំពីស្រុក

ឃុំជាច្រើន មិនកំណត់ រួមគ្នាកើតបានជាស្រុក ហើយមានមន្ត្រីរដ្ឋបាលមួយរូបជាអ្នកកាន់កាប់ការរាជការនៅទីនោះ ដែលគេសន្មតងារថា «ចៅហ្វាយស្រុក» ។ ចៅហ្វាយស្រុកនិមួយៗត្រូវមានស្មៀន, យុក្របាត់ និង បាល័ដ្ឋជួយធ្វើការរៀងរាល់ថ្ងៃផង ។

កិច្ចការអចិន្ត្រៃយរបស់ចៅហ្វាយស្រុកមានដូចតទៅ៖

— ធ្វើសេចក្ដីចំរើនដល់ស្រុក ដោយសង់ផ្លូវគមនាគមន៍មានថ្នល់ និង ស្ពានជាដើម ។ ក្រៅពីនេះត្រូវចេះណែនាំអ្នកស្រុកឲ្យសង់សាលារៀន, សាងទំនប់ទឹកសំរាប់ធ្វើស្រែ ឬ ជីកព្រែកបញ្ចូលល្បប់ទៅក្នុងចំការច្បារដំណាំ ។

— ពន្យល់ ឬ ណែនាំបណ្ដារាស្ត្រឲ្យស្គាល់វឌ្ឍនធម៌អារ្យធម៌គ្រប់យ៉ាង ហើយនឹងករណីយកិច្ចជាពលរដ្ឋល្អប្រសើរផង ។

— រក្សាសេចក្ដីសុខដល់ប្រជារាស្ត្រ ខាងផ្នែកសុខភាពក្ដី ខាងផ្នែកសន្តិសុខក្ដី ។

– ថែរក្សាទ្រព្យសម្បត្តិជាតិ ដូចជាថ្នល់, ស្ពាន, សាលា, ព្រែក, ស្ទឹង, ព្រៃឈើ ជាដើម និង ដឹកនាំអ្នកស្រុកឲ្យចេះជួយការពារទ្រព្យធនធានទាំងនេះផង ។

– កាន់បញ្ជីប្រជារាស្ត្រ ដែលស្ថិតនៅក្នុងស្រុករបស់ខ្លួន ដើម្បីឲ្យដឹងជាក់ប្រាកដពីចំនួនមនុស្សស្រី-ប្រុស, ក្មេង-ចាស់ ក្នុងមួយឆ្នាំកើតប៉ុន្មាន, ស្លាប់ប៉ុន្មាន ?

– ប្រមូលប្រាក់ពន្ធដារដែលទារបានពីបណ្ដាជនចំណុះស្រុក យកទៅដាក់ឃ្លាំងជាតិឲ្យបានទាន់ពេលវេលា ។

– ជួយដឹកនាំអ្នកស្រុកឲ្យស្គាល់ និងឲ្យស្រឡាញ់របៀបគ្រប់គ្រងរបស់រាជការខាងផ្នែកនយោបាយក្នុងប្រទេសក្ដី ក្រៅប្រទេសក្ដី ។

កិច្ចការជាការកិច្ចរបស់ចៅហ្វាយស្រុកដែលបានរាប់រៀបមកទាំងប៉ុន្មានខាងលើនេះ សុទ្ធសឹងតែទាក់ទងជាមួយនឹងសាលាឃុំជាដំបូង ហើយត្រូវបញ្ជូនបន្តទៅសាលាខេត្តទៀត ។

## សំនួរ

ដូចម្ដេចដែលហៅថាស្រុក ? ស្រុកនិមួយ ៗ មានកំរិតចំនួនឃុំស្មើគ្នា ឬទេ ? អ្នកណាជាអ្នកកាន់កាប់ការរាជការក្នុងស្រុក ? នរណាខ្លះជាអ្នកជួយធ្វើការចៅហ្វាយស្រុក ? មុខងាររបស់ចៅហ្វាយស្រុកធ្វើអ្វីខ្លះ ? សាលាស្រុកធ្វើការទាក់ទងនឹងទីណាខ្លះ ?

# អំពីខេត្ត

ស្រុកតិចច្រើនមិនកំណត់ ប្រជុំគ្នាកើតបានជាខេត្ត ៗ ខេត្តនីមួយ ៗ មានមន្ត្រីថ្នាក់ខ្ពស់ម្នាក់ ហៅថាចៅហ្វាយខេត្ត ជាអ្នកត្រួតត្រាកិច្ចការគ្រប់ចំពូក ជាមួយនឹងសហការី កូឈួយខេត្ត, ចៅហ្វាយស្រុក, បាល័ដ្ឋខេត្ត និងភ្នាក់ងារផ្សេង ៗ ទៀត ដែលធ្វើការក្រោមបង្គាប់ផ្ទាល់ នឹងមាននាយក្រុមរាជការជាតិដទៃ ៗ ទៀត ៗ ក្រុមរាជការទាំងនោះមាន ៖ ក្រុមសាធារណការ, សិក្សាធិការ, សុខាភិបាល, សុរិយោដី, កសិកម្ម, យុត្តិធម៌, នគរបាល, ការពារប្រទេស, ហិរញ្ញវត្ថុ, ឃោសនាការ, គង្គា, រុក្ខា, ប្រមាញ់នឹងនេសាទ, ចលនាយុ-ជនរាជសង្គមនិយមខ្មែរ ជាដើម ៗ

នៅក្នុងខេត្តខ្លះ ដែលពុំសូវមានសកម្មភាពប៉ុន្មាន មានក្រុមរាជការជាច្រើនផ្នែក ដែលធ្វើកិច្ចការនៅក្នុងសាលាខេត្តដែរ ៗ

ខេត្តទាំងឡាយសុទ្ធតែមានឈ្មោះផ្សេង ៗ ពីគ្នា ហើយមានព្រំប្រទល់ជាលក្ខណ៍ត្រឹមត្រូវ ដើម្បីងាយក្នុងការគ្រប់គ្រងមើលខុស-ត្រូវរបស់អ្នករដ្ឋការខេត្តនិមួយ ៗ ។ ឯទំហំផ្ទៃអាណាខេត្តក៏មិនស្មើគ្នាដែរ គឺមានខេត្តខ្លះធំ ខេត្តខ្លះតូច អា-ស្រ័យលើចំនួនមនុស្សបំណុះខេត្ត និង ផលិតផលកើតមានក្នុងខេត្តនោះ ។

នៅប្រទេសកម្ពុជាមាន ១៦ ខេត្ត ដែលមាននាមប្លែក ៗ គ្នា ដូចតទៅ៖ កណ្តាល, កំពង់ចាម, បាត់ដំបង, កំពត, កំពង់ធំ, សៀមរាប, តាកែវ, កំពង់ឆ្នាំង, កំពង់ស្ពឺ, ព្រៃវែង, ស្វាយរៀង, ពោធិសាត់, ក្រចេះ, ស្ទឹងត្រែង, កោះ-កុង និង រតនគិរី ។ ខេត្តទាំង ១៦ ដែលមានរាប់ឈ្មោះខាងលើនេះ សុទ្ធតែមានរដ្ឋការខេត្ត ទទួលបន្ទុកកិច្ចការរដ្ឋការដោយឡែក ៗ ពីគ្នា ។

ការចែកជាខេត្តដូច្នេះ ប្រយោជន៍ឲ្យផលិតផលក្នុងផ្នែកភូមិភាគត្រង់នោះ ៗ បានកើនចំរើនឡើងជាលំដាប់ ។

## សំនួរ

ដូចម្ដេចហៅថាខេត្ត ? ខេត្តនិមួយ ៗ មានទំហំប៉ុន ៗ គ្នា ឬទេ ? អ្នកណាជាអ្នកត្រួតត្រាបណ្ដារាស្ត្រជំនួសរាជការផែនដី ? សហការីរបស់ចៅហ្វាយខេត្តមាននរណាខ្លះ ? ទំហំនៃខេត្តនីមួយ ៗ តើគេសំគាល់ដោយសារអ្វី ? រាជ-ការខេត្ត មានមុខងារដូចម្ដេចខ្លះ ? ប្រទេសកម្ពុជាមានខេត្តប៉ុន្មាន ? ចូររាប់ឈ្មោះខេត្តទាំងនោះ ។

# បណ្ដាជនចំណុះឃុំ

ឃុំនិមួយ ៗ មានមនុស្សរស់នៅតិចច្រើនតាមឃុំដែលគេចុះបញ្ជីមនុស្សចំណុះឃុំ គឺមានជនជាតិខ្មែរ និងជនជាតិដទៃដែលមករស់នៅក្នុងដែនដីខ្មែរដូចជាចិន យួន ជាដើម ។

ជនទាំងនេះ ម្នាក់ ៗ ត្រូវស្គាល់ករណីយកិច្ចរបស់ខ្លួនហើយបំពេញដោយខានពុំបាន គឺថាមនុស្សម្នាក់ ៗ ត្រូវបង់ពន្ធដារតាមបញ្ញត្តិច្បាប់ ៗ គ្រាណាមានអាសន្នណាមួយ ដូចមានកើតជម្ងឺ ឬ កើតចលាចលដោយមនុស្សទុច្ចរិតបង្កបង្កើតឡើង បណ្ដាជនត្រូវរួមកម្លាំងគ្នាជាមួយមន្ត្រីឃុំ ដើម្បីបង្ក្រាបអាសន្នមហន្តរាយនោះឲ្យស្ងប់ទៅវិញ ។ អ្នកណាជាមនុស្សចំណូលថ្មីត្រូវទៅប្ដឹងមេឃុំឲ្យបានដឹងផង ហើយបើឈប់លែងនៅទីនោះទៅវិញ ក៏ត្រូវទៅប្ដឹងមេឃុំដែរ ដើម្បីឲ្យមេឃុំលុបឈ្មោះចេញពីបញ្ជី ។ បើមានកូនកើត, មានរៀបមង្គលការ ឬ មានមរណភាព ក៏ត្រូវទៅប្ដឹងមេឃុំឲ្យចុះក្នុងបញ្ជីអត្រានុកូលដ្ឋានដែរ ។

នៅពេលស្រុកមានកើតជម្ងឺ ហើយមានភ្នាក់ងារក្រុមសុខាភិបាលចេញទៅចាក់ថ្នាំបង្ការរោគ បណ្ដាជនក្នុងឃុំ ត្រូវនាំគ្នាមកចាក់ថ្នាំ ឬបណ្ដុះអុតជាកាតព្វកិច្ច ។ ក្រៅពីនេះ ជនចំណុះឃុំត្រូវធ្វើពលីកម្មក្នុងកិច្ចការកសាងផ្សេង ៗ ដែលជាប្រយោជន៍សាធារណៈ ដូចជាសាងទំនប់ទឹក, លើកថ្នល់ធ្វើគមនាគមន៍, កសាងសាលារៀន, សង់ស្ពាន ។ ល ។ ប្រសិនជាបានដឹងរឿងអាថ៌កំបាំងអ្វីមួយ ដែលបំរុងកើតចលាចលក្នុងភូមិ ជនទាំងនោះត្រូវម្នីម្នានាំដំណឹងនេះ ទៅប្ដឹងដល់មន្ត្រីឃុំ ដើម្បីកំចាត់អំពើទុច្ចរិតនោះទៅវិញ ។

បើមានកូនចៅ មានអាយុ ៦ ឆ្នាំល្មមឲ្យទៅរៀនសូត្របានហើយ ត្រូវនាំយកឲ្យទៅចូលរៀនឯសាលាដែលស្ថិតក្នុងភូមិ ឬក្នុងឃុំរបស់ខ្លួន ។ កាលណារាជការមានការពិគ្រោះពីបញ្ហានយោបាយ ដូចជាការបោះឆ្នោត ឬធ្វើប្រជាមតិ សួរយោបល់ពីអ្វី បណ្ដារាស្ត្រត្រូវតែបញ្ចេញមតិជូនរាជការ ។

## សំនួរ

អ្នកណាខ្លះដែលជាមនុស្សចំណុះឃុំ ? ជនជាតិដទៃពីខ្មែររាប់ថាជាមនុស្សចំណុះឃុំបានឬទេ ? ករណីយកិច្ចរបស់បណ្ដាជនក្នុងឃុំត្រូវធ្វើដូចម្ដេចខ្លះ ? ពេលស្រុកកើតអាសន្ន តើបណ្ដាជនចំណុះឃុំត្រូវកាន់ចិត្តដូចម្ដេច ? ពលរដ្ឋចំណុះឃុំ ត្រូវធ្វើពលីកម្មចំពោះកិច្ចការអ្វី ?

# បញ្ជីអត្រានុកូលដ្ឋាន

មេឃុំជាមន្ត្រីកាន់បញ្ជីអត្រានុកូលដ្ឋាន គឺមានបញ្ជីកំណើត, អាពាហ៍ពិពាហ៍ និងមរណភាព ។

កាលណាមានកូនកើតភ្លាម ឪពុកម្តាយ ឬ ជនដែលបានដឹង ត្រូវទៅប្តឹងមេឃុំ ក្នុងរវាងមួយសប្តាហ៍ ឲ្យចុះឈ្មោះកូន និង ថ្ងៃខែដែលកើតរបស់កូននោះក្នុងបញ្ជីអត្រានុកូលដ្ឋាន កំណើត ។ រួចហើយត្រូវសុំចុងសន្លឹកស្រង់សេចក្តីពីបញ្ជីដើម និង ឲ្យមេឃុំបញ្ជាក់ចុះហត្ថលេខា និង បោះត្រាត្រឹមត្រូវសំរាប់ប្រើការ នៅពេលដែលកូននោះត្រូវចុះឈ្មោះចូលរៀន, ពេលប្រឡងផ្សេង ៗ ឬ ក្នុងការសុំលិខិតអនុញ្ញាតផ្សេង ៗ ទៀត ។

កាលណាមានកូនចៅរៀបអាពាហ៍ពិពាហ៍, ឪពុកម្តាយខាងប្រុសត្រូវទៅប្តឹងមន្ត្រីឃុំ ឲ្យចេញប្រកាសផ្សាយដំណឹងក្នុងកំណត់ ៨ ថ្ងៃមុនពេលរៀបការ ។ ប្រកាសនេះត្រូវធ្វើជា

ពីរច្បាប់គឺមួយបិទនៅសាលាឃុំ នឹង មួយច្បាប់ទៀតបិទនៅកន្លែងដែលត្រូវរៀបអាពាហ៍ពិពាហ៍ ប្រយោជន៍ក្រែងមានជនណាចាក់ចង់នឹងឈ្មោះសាមីខ្លួនប្រុស-ស្រីចូលមកតវ៉ា ។ បើផុតកំណត់នេះហើយ ការតវ៉ា នឹងទុកជាឥតបានការ ។ លុះរៀបមង្គលការរួច ឪពុកម្ដាយតាំងសង់ខាង នឹង សាមីខ្លួនតាំងពីររូប ត្រូវនាំសាក្សី ២ នាក់ទៀត ទៅសុំឲ្យមេឃុំចុះសំបុត្រអាពាហ៍ពិពាហ៍ក្នុងបញ្ជីអត្រានុកូលដ្ឋាន ។ រួចហើយ សាមីខ្លួនត្រូវសុំសេចក្ដីចម្លងសំរាប់យកមកប្រើការ ។

កាលណាមានមនុស្សស្លាប់ ម្ចាស់សពឬអ្នកដែលបានដឹង ត្រូវទៅប្ដឹងមេឃុំឲ្យចុះមរណភាពក្នុងបញ្ជីអត្រានុកូលដ្ឋានជាដរាប ។ សំបុត្រមរណភាពត្រូវចំឡងទុកប្រើការផ្សេង ៗ ដូចលិខិតមុន ៗ ដែរ ។

ការប្ដឹងសុំចុះបញ្ជីអត្រានុកូលដ្ឋាននេះ ត្រូវធ្វើក្នុងកំរិត ៧ ថ្ងៃក្រោយពីមានហេតុការណ៍នោះ ៗ បើហួសពីកំណត់ពេល

នេះ ត្រូវធ្វើពាក្យប្ដឹងទៅសាលាលហុ ឬ សាលាដំបូង(១) ដើម្បីសុំការវិនិច្ឆ័យពីលោកចាងហ្វាងនៃសាលានោះ ចេញសាល-ក្រមជំនុស ហើយត្រូវយកសាលក្រមនេះ ទៅសុំឲ្យមេឃុំចុះក្នុងបញ្ជីអត្រានុកូលដ្ឋានទៀតទើបបានការ ។ បើចុះរួចហើយសាមីជនកុំភ្លេចសុំចំឡងចុងសន្លឹក ដោយមានបញ្ជាក់ត្រឹមត្រូវសំរាប់ទុកប្រើការតទៅ ដូចមានពោលមកខាងលើស្រាប់ ។ បើសុំសាលក្រមជំនួសដូច្នេះ ម្ចាស់ខ្លួនត្រូវបង់ពិន័យ ប្រាក់ជាបទលហុ ដោយខ្លួនធ្វេសប្រហែសមិនទៅប្ដឹងកជការមុខក្រសួងឲ្យទាន់ពេលវេលា ។ បញ្ជីអត្រានុកូលដ្ឋានត្រូវមានជាពីរច្បាប់ គឺមួយច្បាប់ដំកល់នៅសាលាស្រុក ដែលជាអ្នកគ្រប់គ្រងលើឃុំទាំងអស់ និងមួយច្បាប់ទៀតដំកល់នៅសាលាលហុ ឬនៅសាលាដំបូង ។

---

១– សព្វថ្ងៃ គេបានប្រគល់ភារៈនេះទៅសាលាស្រុក ដោយមានសមុហ-បញ្ជីម្នាក់ នៅកាន់ការនេះ និង ចៅហ្វាយស្រុកស្ដីទីជាចាងហ្វាងសាលាលហុ សំរាប់វិនិច្ឆ័យរឿងអត្រានុកូលដ្ឋាន ។

## សំណួរ

ដូចម្ដេចហៅថាអត្រានុកូលដ្ឋាន ? នៅពេលមានកូនកើត, រៀបការកូន នឹងមានមនុស្សស្លាប់ គេត្រូវធ្វើដូចម្ដេច ? នរណាជាមន្ត្រីអត្រានុកូលដ្ឋាន ? បើនរណាធ្វេសប្រហែសក្នុងការនេះ គេត្រូវធ្វើដូចម្ដេច ? បុងសន្លឹកនៃបញ្ជីអត្រានុកូលដ្ឋានមានប្រយោជន៍យ៉ាងណាខ្លះ ?

# អំពីក្រុងនិងរាជធានី

ដែលហៅថាក្រុងក្នុងទីនេះ គឺពោលសំដៅទីក្រុងដោយឡែក មិនមែនជាប់ទាក់ទងខាងការគ្រប់គ្រងជាមួយខេត្តណាមួយឡើយ ។

ការងាររាជការក្រុង មិនខុសគ្នាពីការងាររបស់រាជការខេត្តទេ គឺមានមន្ត្រីរដ្ឋបាលថ្នាក់ខ្ពស់មួយរូប ជាអ្នកត្រួតត្រានៅក្នុងដំបន់នោះ ហៅថា «ចៅហ្វាយក្រុង» ។ សហការីរបស់ចៅហ្វាយក្រុង មានកូឈួយ, បាល័ដ្ឋ, ស្មៀន និងនាយក្រុមរាជការផ្សេងៗ ដែលនៅក្នុងបន្ទុកផ្ទាល់របស់សាលាក្រុង ។ ក្រុងណាមានមនុស្សច្រើន និងវិសាលភាពធំទូលាយត្រូវបែកចេញជាសង្កាត់ដោយឡែកៗពីគ្នា និងមានតាំង នាយសង្កាត់មួយរូបៗ ធ្វើជាអ្នកត្រួតត្រាកិច្ចការរាជការក្នុងសង្កាត់ទាំងនោះ ។ នាទីសាលាក្រុង ត្រួតត្រាកិច្ចការបានតែក្នុងមួយមណ្ឌលក្រុងប៉ុណ្ណោះ ពុំមែនដូចសាលាខេត្ត អាចត្រួតត្រា

បានទៅគ្រប់ស្រុក គ្រប់ឃុំ ពេញមួយខេត្តនោះឡើយ ។ ភារៈធំរបស់សាលាក្រុង ប្លែកពីសាលាខេត្ត ត្រង់ដែលរៀបចំតុបតែងលំអទីក្រុងឲ្យបានប្លែក និង ឲ្យបានសមរម្យខាងផ្នែកទេសចរណ៍ផង ។

នៅប្រទេសកម្ពុជាយើងមានក្រុងបី គឺ ៖ ក្រុងភ្នំពេញ, ក្រុងព្រះសីហនុ និង ក្រុងកែប ។ ក្រុងទាំងបីនេះ មានតែក្រុងភ្នំពេញ ដែលជារាជធានី គឺមានព្រះមហាក្សត្រគង់នៅ មួយទៀត ដែលមានវិសាលភាពធំទូលាយ និង មានមនុស្សកុះករច្រើនជាអនេក ហេតុដល់ទៅចែកជា ៧ សង្កាត់ ។ ឯក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រអន្តរជាតិមួយ យ៉ាងសំខាន់នៃប្រទេសកម្ពុជា និង ក្រុងកែប ដែលជារមណីយដ្ឋានខាងទេសចរណ៍ សុទ្ធសឹងជាក្រុងថ្មី ដែលរាជការកំពុងតែចាត់ចែងរៀបចំបង្កើនឲ្យបានធំទូលាយ និង សមរម្យឡើងទៀត ជារៀងរាល់ថ្ងៃ ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា
បណ្ណាល័យជាតិ
ទីលេខក្រុង : ..........

## សំនួរ

ដូចម្តេចហៅថាក្រុង ? តើក្រុងនឹងទីវត្តខុសគ្នាដូចម្តេច ? ភារៈរាជការក្រុងធ្វើអ្វីខ្លះ ? នរណាជាអ្នកកាន់កាប់ការរាជការក្រុង ? មន្ត្រីនោះងារជាអ្វី ? មាននរណាជួយធ្វើការខ្លះ ? ប្រទេសកម្ពុជាមានក្រុងប៉ុន្មាន ? ឈ្មោះក្រុងអ្វីខ្លះ ? ក្រុងណាធំជាងគេ ? ព្រោះអ្វី ? ក្រុងបែបណាដែលហៅថារាជធានី ?

★ ★

# អំពីប្រាក់ថវិកា

ដើម្បីរៀបចំឲ្យប្រទេសបានរុងរឿងដោយគោគទ្រព្យទឹង ការកសាងផ្សេង ៗ រាជការបានបង្កើតថវិកាមួយ សំរាប់គ្រោងការប្រាក់ចំណូល–ចំណាយជាចាំបាច់ ក្នុងការគ្រប់គ្រងរដ្ឋ ៗ ថវិកានេះ គឺបណ្ដាជនជាពលរដ្ឋគ្រប់គ្នាជាអ្នកបង់រួបរួល ក្នុងឃ្លាំងជាតិ ដោយការបង់ពន្ធដារសព្វសារពើ ៗ ប្រាក់ថវិកាមានច្រើនបែប គឺប្រាក់ពន្ធនានា ដែលបណ្ដាជនចំណុះឃុំបង់ពន្ធបន្ទាប់បន្សំជាប្រយោជន៍ថវិកាឃុំ ចំពោះឃុំណាដែលធំ ៗ មានមនុស្សនៅច្រើន នឹងមានសកម្មភាពខាងពាណិជកម្ម ៗ ឯឃុំដទៃដែលគ្មានថវិកាឃុំ មេឃុំត្រូវយកប្រាក់ពន្ធដែលទារបានទៅជូនចៅហ្វាយស្រុក ដើម្បីបញ្ជូលទៅក្នុងឃ្លាំង ប្រាក់ប្រចាំខេត្ត ៗ ឯទីក្រុងភ្នំពេញ ក៏មានថវិកាមួយដែរ ហៅថាថវិកាក្រុង ៗ ថវិកានេះគឺប្រាក់ចំណូលគ្រប់ជំពូកដែលបានមកពីបណ្ដាជននៅក្នុងទីក្រុង ៗ បណ្ដាថវិកាទាំងបីផ្នែក គឺថវិកា

ឃុំ ថវិកាខេត្ត នឹងថវិកាក្រុងនេះ បើប្រើក្នុងការចំណាយក្នុងនាទីរៀងខ្លួនរួចហើយ, ហើយនៅមានសល់ទៀត ត្រូវនាំប្រាក់ដែលនៅសល់នោះ បញ្ចូលទៅក្នុងថវិកាធំមួយទៀត ហៅថាថវិកាជាតិ ។

ប្រាក់ចំណាយរបស់រាជការសព្វសារពើក្នុងកិច្ចស្ថាបនាអ្វីមួយ ឬការរៀបចំរបៀបគ្រប់គ្រងគ្រប់ជំពូក សុទ្ធតែអាស្រ័យលើថវិការៀងរាល់ចំណែកទាំងអស់ ។ បើប្រាក់ថវិកាឃុំ, ខេត្ត, ក្រុង មានចំនួនមិនគ្រប់គ្រាន់ ត្រូវយកថវិកាជាតិផ្តល់បំពេញឡើងតាមកម្លាំងធ្វើទៅបាន ។ ប្រាក់ថវិកាជាតិនេះហើយ ដែលមានចំនួនច្រើនលើសលប់ជាងគេ សំរាប់បំពេញតាមគំរោងការដែលរាជការត្រូវចាត់ចែងធ្វើ ។

ដូចនេះ ត្រូវតែពលរដ្ឋម្នាក់ៗ កុំធ្វេសប្រហែសក្នុងការបង់ពន្ធដារសព្វសារពើ ជូនរាជការ ដើម្បីជួយពួតកម្លាំងគ្នាយកទៅកសាងប្រទេសជាតិ ។

## សំណួរ

ដើម្បីឲ្យប្រទេសមានភោគទ្រព្យ រោងការត្រូវធ្វើដូចម្ដេច ? ថវិកាមានប៉ុន្មានយ៉ាង ? ចូរនិយាយពីថវិកានិមួយៗ ។ ប្រាក់ថវិកាជាតិបានពីណាមក ? បើគេចាយថវិការៀងរាល់ខែហើយនៅតែខ្វះប្រាក់ទៀត តើគេបានប្រាក់ឯណាមកបំពេញ ? បណ្ដាជននាំគ្នាបង់ពន្ធដារនេះ គេទុកធ្វើការអ្វី ? រោងការអាចសំរេចទៅតាមគំរោងការធំៗ បានដោយសារអ្វី ?

# ប្រាក់ពន្ធ និង ប្រាក់អាករ

ប្រាក់ដែលពលរដ្ឋគ្រប់គ្នាបង់ជូនទៅរាជការ គេហៅថា ប្រាក់ពន្ធ និង ប្រាក់អាករ ។

ពន្ធចែកជាពីរយ៉ាងគឺ ៖

១– ពន្ធចំពោះ .– ពន្ធចំពោះ គឺប្រាក់ចំណូលដែលរាជការបានគ្រោងបញ្ជីតាមឈ្មោះរួចជាស្រេច ដូចជាពន្ធដី, ពន្ធប៉ាតង់ ។ល។ ដូចនេះ ពន្ធចំពោះជាពន្ធដែលជនជាប់ឈ្មោះចៀសពុំផុតឡើយ ។ ការរឹងទទឹងដោយឥតហេតុផល ពុំព្រមបង់ពន្ធត្រូវផ្ដន្ទាទោសដល់ទ្រព្យសម្បត្តិ និង រូបកាយនៃអ្នកជាប់ពន្ធ ។

២– ពន្ធឥតចំពោះ .– ពន្ធប្រភេទនេះ រាជការឥតមានបញ្ជីរាយឈ្មោះគ្រោងទុកជាមុនទេ តែជនម្នាក់ៗ ដែលបានប្រព្រឹត្តនូវអំពើអ្វីមួយដែលរាជការតម្រូវយកពន្ធនោះ ដូចជាការទិញវត្ថុប្រើប្រាស់ផ្សេងៗ ការប្រើតែមប្រ៊ិ ផលរបរលក់ដូរមានប្រាក់ចេញចូលគល់ថ្លៃ ជាដើម ។

ដែលហៅថាអាករ គឺជាពន្ធម្យ៉ាងមានសណ្ឋានប្រហែល នឹងពន្ធឥតចំពោះដែរ គឺថាពលករគ្មានបញ្ជីគ្រោងចំនួនប្រាក់ ពន្ធអាករនេះទុកជាមុនទេ ។ ទំនិញសព្វបែបសព្វយ៉ាងដែលលក់ពីម្នាក់ទៅម្នាក់ គេត្រូវហូតអាករលើថ្លៃទំនិញទាំងនោះ ។ ទេះឡាន ឬទេះកាលយន្ត ត្រូវបង់អាករលើប្រាក់ចំណូលជូនពលករដែរ ។ ចំពោះវត្ថុដែលឈ្មួញនាំពីបរទេសចូលមកលក់ក្នុងស្រុក ឬ បញ្ចេញពីស្រុកខ្មែរទៅលក់បរទេស ក៏ត្រូវជាប់ពន្ធអាករនេះដែរ ។

មានពន្ធអាករមួយទៀត គេហៅថា រដ្ឋាករ ដែលគេហូតលើវត្ថុដែលកើតនៅក្នុងស្រុក ដូចជា ស្រា, ថ្នាំជក់, បារី, ឈើគូស ជាដើម ។ ការហូតអាករនេះត្រូវនៅលើក្រុមគយនឹងរដ្ឋាករ ។ អាជីវកម្មជាប្រយោជន៍ពលករ ដែលរដ្ឋឬក្រុងកាន់កាប់ផ្ទាល់ក៏ហៅថា អាករដែរ ដូចជា ការស៊ីផ្សារ ជាដើម ។

ក្រុមពលករខាងពន្ធ ឬខាងគយ នឹងរដ្ឋាករ សុទ្ធតែនៅក្រោមអំណាចក្រសួងហិរញ្ញវត្ថុទាំងអស់ ។

## សំនួរ

ដូចម្ដេចហៅថាពន្ធ ? ពន្ធមានប៉ុន្មានយ៉ាង ? ចូរនិយាយពីពន្ធចំពោះ និង ពន្ធឥតចំពោះ ។ ពន្ធម្យ៉ាងទៀតដែលហៅថា អាករ តើមានសណ្ឋានដូចម្ដេច ? គេហូតអាករលើអ្វីខ្លះ ? រដ្ឋាករគេហូតពីលើរបរអ្វីខ្លះ ? ក្រុមរាជការខាងពន្ធទាំងនេះ នៅក្រោមអំណាចក្រសួងណា ?

# សិទ្ធិ-សេរីភាព និងករណីយកិច្ច របស់ពលរដ្ឋ

ជនជាតិខ្មែរទាំងឡាយមានសេរីភាព អាចធ្វើអ្វីបានគ្រប់យ៉ាង កុំឲ្យតែប៉ះពាល់សិទ្ធិអ្នកដទៃ ។ អ្វីដែលច្បាប់មិនបង្គាប់ឲ្យធ្វើទេ ជនណាក៏ដោយ ពុំអាចត្រូវនរណាមួយបង្ខិតបង្ខំឲ្យធ្វើតាមបង្គាប់ខ្លួនបានឡើយ ។ បើនឹងចោទចាប់ ឬឃុំឃាំងជនណាមួយបាន លុះតែជននោះបានប្រព្រឹត្តកំហុសដ៏ជាក់ស្តែង ហើយចៅក្រមបានពិនិត្យថាការឃុំឃាំងនេះ ត្រឹមត្រូវតាមច្បាប់ផង ។ ដរាបណាតុលាការមិនទាន់ប្រកាសថា អ្នកត្រូវចោទមានទោសទេ ដរាបនោះ ត្រូវទុកអ្នកត្រូវចោទជាមនុស្សឥតទោស ។ ខេមរជនទាំងឡាយមិនអាចត្រូវនិរទេសចេញពីដែនខ្មែរបានឡើយ ។ ឯសេរីភាពខាងជំនឿ ត្រូវបើកឲ្យមានដោយបរិបូរណ៌ ទោះបើខាងជំនឿសាសនា ក៏ត្រូវបើកតាមចំណង់ដែរ ។ ឯសេរីភាពខាងការនិយាយ, ការសរសេរ, ការ

ព្រោះពុម្ពផ្សាយ, ខេមរជនទាំងឡាយត្រូវមានដោយបរិបូណ៌ កុំឲ្យតែញុំាងឲ្យខូចការស្ងប់រៀបរយរបស់មហាជន ។ ឯការថ្លែងមតិនេះសោត ក៏មិនត្រូវមាននរណាបង្គាប់ឲ្យថាដូចនេះឬដូចនោះបានឡើយ ។ មិនតែប៉ុណ្ណោះខេមរជន មានសិទ្ធិប្រមូលគ្នាជាសមាគមដោយសេរីទៀត, រៀរលែងតែសមាគមនោះធ្វើឲ្យខូចសេរីភាពនានាដែលច្បាប់ធានាអះអាងឲ្យមាន ។ ឯការប្រជុំ ក៏មានសេរីភាពដូចគ្នាដែរ ។ ជនជាតិខ្មែរម្នាក់ៗ អាចទទួលដំណែងរាជការបានដូចៗគ្នា ក្រៅពីសមត្ថភាព និងគុណសម្បត្តិរបស់សាមីខ្លួន គ្មានអ្វីជាឧបសគ្គបានឡើយ ។ ឯការធ្វើពាក្យបណ្ដឹងសុំទៅអ្នកកាន់អំណាចសាធារណៈ ក៏មានសិទ្ធិធ្វើបានដោយសេរីដែរ ដើម្បីញុំាងឲ្យមានការពិចារណាបញ្ហាទាំងឡាយ ដែលជាប្រយោជន៍បុគ្គល ឬដល់មហាជន ។

ខេមរជនត្រូវមានករណីយកិច្ចប្រតិបត្តិច្បាប់ការពាររដ្ឋហើយត្រូវជួយរដ្ឋាភិបាលដោយបង់ពន្ធដារ ដែលមានបញ្ញត្តិទុកក្នុងច្បាប់នឹងត្រូវមានចិត្តស្មោះត្រង់ចំពោះព្រះមហាក្សត្រផង ។

## សំណួរ

ជនជាតិខ្មែរ អាចត្រូវបង្ខិតបង្ខំឲ្យធ្វើតាមមតិគេបានទេ ? ដើម្បីនឹងឃុំឃាំងជនណាមួយបាន ទាល់តែមានទោសជាក់ស្តែងម្តេចខ្លះ ? បើតុលាការមិនទាន់ប្រកាសថាមានទោសទេ អ្នកត្រូវចោទត្រូវទុកជាអ្វី ? គេអាចធ្វើពាក្យប្តឹងទៅអ្នកកាន់អំណាចបានដោយករណីយ៉ាងណា ? បណ្តាជនខ្មែរមានករណីយកិច្ចធ្វើអ្វីខ្លះ ?

# អំពីច្បាប់ និង អំណាច

ច្បាប់ជាកិច្ចធានាអះអាងឲ្យខេមរជនប្រើសេរីភាព និងសិទ្ធិទាំងពួង ហើយឲ្យមានសិទ្ធិប្តឹងដល់តុលាការជំនុំជំរះផង ៗ ឯការខ្វះខាតធនធានមិនអាចជាឧបសគ្គក្នុងការឲ្យតុលាការជំនុំជំរះនោះបានឡើយ ៗ ច្បាប់ទាំងឡាយនឹងអនុវត្តទៅបានដោយមានកំណត់ពេលដូចតទៅ ៖ នៅភ្នំពេញ កំណត់មួយថ្ងៃគត់ ក្រោយដែលបានចុះផ្សាយក្នុងសៀវភៅរាជកិច្ចហើយ ៗ ចំណែកនៅឯទៀត គឺនៅខេត្តក្រៅ ៗ មានស្រុកនីមួយ ៗ ជាដើម កំណត់ពេលប្រាំថ្ងៃគត់ ក្រោយដែលសៀវភៅរាជកិច្ចនោះបានទៅដល់សាលាស្រុកហើយ ៗ ក្នុងករណីដែលច្បាប់នោះត្រូវចាត់ទុកជាការប្រញាប់ ច្បាប់ត្រូវប្រើតាមបានក្រោយដែលបានយកទៅបិទផ្សាយនៅសាលាក្រុង ឬ សាលាស្រុកហើយ ៗ

អ្នកដែលមានសិទ្ធិតែងច្បាប់បាននោះគឺ៖ ព្រះមហាក្សត្រ,

គណៈរដ្ឋមន្ត្រី រដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រ ។ ប៉ុន្តែទោះបីជាក្រុមណាតែងក៏ដោយ ច្បាប់នោះត្រូវតែក្រាបបង្គំទូលថ្វាយដល់ព្រះមហាក្សត្រដែរ ព្រោះច្បាប់ចែងថា អំណាចគ្រប់យ៉ាង សុទ្ធសឹងមកពីព្រះមហាក្សត្រទាំងអស់ ហើយអំណាចទាំងនោះត្រូវតាមបទបញ្ញត្តិ នៃរដ្ឋធម្មនុញ្ញផង ។

រដ្ឋសភាជាអ្នកកាន់អំណាចនីតិបញ្ញត្តិក្នុងព្រះបរមនាមនៃព្រះមហាក្សត្រ គឺជាអ្នកតែងច្បាប់ឲ្យគេអនុវត្តិតាម ។

គណៈរដ្ឋមន្ត្រីជាអ្នកកាន់អំណាចនីតិប្រតិបត្តិក្នុងព្រះបរម-នាមនៃព្រះមហាក្សត្រ គឺជាអ្នកអនុវត្តិច្បាប់ ដែលដាក់ឲ្យប្រើជាធរមានបញ្ញត្តិ ។

សាលាជំនុំជំរះក្តីទាំងឡាយ ជាអ្នកកាន់អំណាចតុលាការក្នុងព្រះបរមនាមនៃព្រះមហាក្សត្រដែរ គឺជាអ្នកកាត់ក្តីជំណាងព្រះរាជា ។

ច្បាប់ទាំងឡាយមិនត្រូវយកទៅប្រើលើអំពើ ដែលកន្លង

ហួសទៅហើយបានឡើយ វៀរលែងតែមានបទបញ្ញត្តិពិសេស ដ៏ជាក់លាក់ ។ យើងគួរសំគាល់ថា ច្បាប់ជាការសម្តែងឆន្ទៈរបស់ប្រជាជាតិទាំងមូល គឺអនុវត្តទៅលើជនទាំងអស់ ពោលគឺពលរដ្ឋណាមួយ ក៏នៅក្រោមអំណាចច្បាប់ដែរ ។

## សំនួរ

តើគេអនុវត្តច្បាប់តាមកំណត់ពេលដូចម្តេច ? អ្នកណាដែលអាចតែងច្បាប់បាន ? ហេតុដូចម្តេចបានជាគេថាអំណាចគ្រប់យ៉ាង សុទ្ធសឹងមកពីព្រះមហាក្សត្រ ? ច្បាប់អាចអនុវត្តទៅលើហេតុ ដែលកន្លងហួសទៅហើយបានឬទេ ? អ្នកណាខ្លះនៅក្រោមអំណាចច្បាប់ ?

# ច្បាប់រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា កើតឡើងដោយសារគណៈកម្មការចំរុះមួយព្រាងឡើង ។ កាលពី គ.ស. ១៩៤៥ បណ្ដាជនខ្មែរបាននាំគ្នាបោះឆ្នោតជ្រើសរើសរដ្ឋសភាបណ្ដោះអាសន្ន ដើម្បីដំណាងខ្លួនទៅពិនិត្យសម្រេចទុកច្បាប់នេះជាបានការ ។ លុះមកដល់ គ.ស. ១៩៤៧ ទើបមានការសម្ពោធច្បាប់នេះយ៉ាងឧឡារិក ដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្ដេចព្រះ នរោត្តម-សីហនុវរ្ម័ន ព្រះអង្គទ្រង់បានប្រោសប្រទានច្បាប់នេះដល់ប្រជារាស្ត្រខ្មែរ ជាទីស្នេហារបស់ព្រះអង្គពីថ្ងៃទី ៦ ឧសភា ១៩៤៧ ។

ច្បាប់នេះបានបើកសិទ្ធិ-សេរីភាព ឲ្យបណ្ដាជនខ្មែរជាច្រើនទូលំទូលាយ ហើយជាច្បាប់ធានាអះអាងនូវសិទ្ធិ-សេរីភាព ដែលបើកឲ្យមាននោះផង ។ ច្បាប់នេះចែកចេញជា១០ ចំពូកគឺ ៖ ចំពូកទីមួយ ស្ដីពីធម្មជាតិ និងសណ្ឋានរបស់រដ្ឋ,

ចំពូកទី ២ ស្តីពីសិទ្ធិ-សេរីភាព និងករណីយកិច្ចរបស់ខេមរជន, ចំពូកទី ៣ ស្តីពីច្បាប់និងអំណាច, ចំពូកទី ៤ ស្តីពីព្រះមហាក្សត្រិយ៍, ចំពូកទី ៥ ស្តីពីរដ្ឋសភា, ចំពូកទី ៦ ស្តីពីក្រុមប្រឹក្សាព្រះរាជាណាចក្រ, ចំពូកទី ៧ ស្តីពីសភាប្រជារាស្ត្រប្រចាំខេត្ត និង រាជធានី, ចំពូកទី ៨ ស្តីអំពីសមាជជាតិ, ចំពូកទី ៩ ស្តីពីគណៈរដ្ឋមន្ត្រី, ចំពូកទី ១០ ស្តីពីអំណាចតុលាការ និង ចំពូកទី ១១ ស្តីពីបញ្ញត្តិទូទៅ ។

គ្រាដែលកសាងជាដំបូង ច្បាប់នេះមានតែ ៩ ចំពូក និងមាន ១០៧ មាត្រាប៉ុណ្ណោះ ។ លុះមកដល់ គ.ស. ១៩៥៥ នៅពេលដែលចលនាសង្គមរាស្ត្រនិយម ដែលមានសម្តេចព្រះឧបយុវរាជជាប្រធាន មានជោគជ័យក្នុងការបោះឆ្នោតសាកល ហើយឡើងកាន់កាប់ការផែនដីនោះ ក៏បើកធ្វើសមាជជាតិ ដើម្បីឲ្យរាស្ត្រប្តូរយោបល់គ្នាក្នុងការកែប្រែ និង បន្ថែមមាត្រាថ្មីខ្លះទៀត ។ ទើបសព្វថ្ងៃនេះឃើញមានដល់ទៅ ១១ ចំពូកក្នុងរដ្ឋធម្មនុញ្ញ ។

## សំណួរ

រដ្ឋធម្មនុញ្ញកើតពីឆ្នាំណា ? ព្រះរាជាអង្គណាដែលបានប្រទានច្បាប់នេះដល់ប្រជារាស្ត្រ ? ពីថ្ងៃណា ? ច្បាប់នេះមានប៉ុន្មានចំពូក ? និយាយពីអ្វីខ្លះ ? ច្បាប់នេះមានការកែប្រែទេ ? សង្គមរាស្ត្រនិយមមានជោគជ័យនៅឆ្នាំណា ?

# ច្បាប់រដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ

ច្បាប់សំរាប់អនុវត្តក្នុងការជំនុំជំរះក្តីនៅក្នុងប្រទេសកម្ពុជា គឺច្បាប់រដ្ឋប្បវេណី និង ក្រមព្រហ្មទណ្ឌ ។ ច្បាប់ទាំងនេះ មានសណ្ឋានខុសគ្នាដូចតទៅ ៖

ច្បាប់រដ្ឋប្បវេណី ជាច្បាប់មានមកតាំងពីបុរាណច្រើនឆ្នាំ គឺច្បាប់និយមតាមប្រពៃណីរបស់ជាតិដែលធ្លាប់មានមកជាទំនៀមទំលាប់រួចហើយ ។ បើពោលឲ្យខ្លី គឺច្បាប់សម្រាប់ផ្សះផ្សា ឬ សំរុះសំរួលក្នុងការខ្វែងគំនិតគ្នា ឬ ក្នុងបញ្ហាស្មុគស្មាញណាមួយដែលគូសញ្ញាដៃគ្នា មិនបេះដាច់ស្រេចសោះ ។ ដូចជានៅពេលដែលគេបែកមរតក , គេកើតអធិករណ៍ដោយរឿងសម្បត្តិទ្រព្យជាចលនវត្ថុក្តី អចលនវត្ថុក្តី។ ចៅក្រមកាត់ក្តីតាមច្បាប់នេះ រមែងយោលទៅតាមការយល់របស់ខ្លួនផង ដោយសំអាងទៅលើចំឡើយរបស់គូក្តី និងប្រពៃណីនិយមរបស់ប្រទេសដែលធ្លាប់មានមកផង ។ ច្បាប់

រដ្ឋប្បវេណីរបស់ខ្មែរយើង បានរៀបចំឡើង ទាំងមានការកែប្រែជារឿយៗពីច្បាប់ដើម ដើម្បីតម្រូវទៅតាមការលូតលាស់នៃប្រទេសជាតិឯករាជ្យនាបច្ចុប្បន្នកាល ៗ ប៉ុន្តែគោលដើម គង់នៅលក្ខខ័ណ្ឌជាច្បាប់មានទំរង់ពិសេសរបស់ជាតិខ្មែរដដែល ៗ

ក្រមព្រហ្មទណ្ឌ ជាច្បាប់ផ្តន្ទាទោសដល់ជនប្រព្រឹត្តល្មើសទោះកំហុសធំក្តី តូចក្តី ៗ ជួនកាលការផ្តន្ទានេះតម្រូវឲ្យបង់ពិន័យជាប្រាក់ក៏មាន ទាំងជួនកាលទៀតត្រូវទណ្ឌកម្មដោយដាក់គុកឲ្យរាងចាលក៏មាន ៗ ច្បាប់នេះ ក៏មានលក្ខណ៍គោលដើម ជាអន្ទើងមកហើយដែរ ប៉ុន្តែខ្មែរយើងបានរៀបចំឲ្យសមរម្យតាមកាលៈទេសៈ ដូចនានាប្រទេសដែរ ៗ

ដូច្នេះច្បាប់នេះ ជាអ្នកដាក់ទោសលើការប្រព្រឹត្តខុសសព្វបែបសព្វយ៉ាង ឬជាច្បាប់អារកាត់ផ្តន្ទាទោស ចំពោះបទល្មើសដែលមានជាក់ប្រាកដ ដើម្បីឲ្យជនទុច្ចរិតនោះរាងចាល ៗ

## សំនួរ

មានច្បាប់អ្វីខ្លះ សំរាប់អនុវត្តក្នុងសាលាជំនុំជំរះក្តីសព្វថ្ងៃ ? ធ្វើម្តេចហៅជា ច្បាប់រដ្ឋប្បវេណី ? គេប្រើច្បាប់នេះក្នុងការជំរះក្តីពីរឿងបែបណា ? ច្បាប់នេះមានដាក់ទោស ឬទេ ? ឯក្រមព្រហ្មទណ្ឌមានអត្ថន័យយ៉ាងណា ? គេសំរាប់ប្រើក្នុងការជំរះក្តីអ្វី ? តើច្បាប់ទាំងពីរយ៉ាងនេះមានមកពីកាលណា ?

# ប្រទេសកម្ពុជា

យើងបានឃើញរួចមកហើយថា ភូមិតិច-ច្រើនរួមគ្នាកើតជាឃុំ, ឃុំរួមគ្នាកើតជាស្រុក, ស្រុករួមគ្នាកើតជាខេត្ត, ខេត្តរួមគ្នាកើតបានជាប្រទេស ។

ប្រទេសកម្ពុជាយើង មានព្រំដែនខណ្ឌសីមាត្រឹមត្រូវ ។ បណ្ដាជនខ្មែររស់នៅក្រោមការគ្រប់គ្រង នៃរដ្ឋាភិបាលមួយ ។ ប្រទេសកម្ពុជា ជារដ្ឋឯករាជ្យពេញលក្ខណៈ មានព្រះមហាក្សត្រគ្រងរាជ្យ តាមលទ្ធិប្រជាធិបតេយ្យ អាស្រ័យរដ្ឋធម្មនុញ្ញ ។ លទ្ធិនេះបើកឲ្យបណ្ដាជនខ្មែរ មានសិទ្ធិបោះឆ្នោតជ្រើសរើសជំណាងខ្លួនឲ្យធ្វើជាសមាជិករដ្ឋសភា ដើម្បីទៅតែងច្បាប់សម្រាប់ប្រទេស និងពិនិត្យកិច្ចការរាជការផ្សេងៗ មានពិនិត្យប្រាក់ចំណូល-ចំណាយជាដើម ។

ប្រទេសកម្ពុជា ប្រកាន់នូវនយោបាយតាំងប្រទេសជារដ្ឋអព្យាក្រឹត្យ គឺមានការប្រាស្រ័យជាមួយនឹងនានាប្រទេស

ដោយឥតមានប្រកាន់បក្សពួកនយោបាយឡើយ ។ កម្ពុជា ជាសមាជិកនៃអង្គការសហប្រជាជាតិ ដូចការប្រទេសនានាដែរ ។ ដោយសារថ្វីព្រះហស្ត នៃ សម្តេចព្រះ នរោត្តម - សីហនុ ឧបយុវរាជជាអគ្គមគ្គុទ្ទេសក៍ នឹង ជាបិតាឯករាជ្យជាតិ ទើបខ្មែរបានចូលជាសមាជិកអង្គការដ៏ធំនេះពីថ្ងៃទី ១៤ ខែធ្នូ គ.ស. ១៩៥៥ ។

ប្រទេសកម្ពុជាមានព្រះមហាក្សត្រគ្រងរាជ្យ ជាអគ្គប្រមុខរដ្ឋ ទ្រង់ជាទីគោរពបូជារបស់ពលរដ្ឋខ្មែរ ជនណាមួយល្មើសពុំបាន ហើយនឹងមានអំណាចគ្រប់គ្រងរដ្ឋ សំខាន់ៗ បីទៀតគឺ៖

- អំណាចនីតិបញ្ញត្តិ ( រដ្ឋសភា )
- អំណាចនីតិប្រតិបត្តិ ( រដ្ឋាភិបាល ),
- អំណាចតុលាការ ( សាលាជំនុំជំរះក្តី ),

ប្រទេសកម្ពុជា ចាប់ផ្តើមនិយមលទ្ធិប្រជាធិបតេយ្យ

គ.ស. ១៩៤៦ គឺមានបង្កើតគណៈកម្មការចំរុះតែងច្បាប់រដ្ឋធម្មនុញ្ញ ក្រោមការដឹកនាំ នៃ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ-យុត្តិវង្ស គឺក្នុងរជ្ជកាលដ៏ត្រចះត្រចង់នៃព្រះបាទសម្តេចព្រះនរោត្តម-សីហានុវរ្ម័ន ។

## សំណួរ

គេស្គាល់ប្រទេសកម្ពុជា ជាជាតិមួយពេញលក្ខណៈដោយសារអ្វី ? កម្ពុជានិយមលទ្ធិអ្វី ? កាន់នយោបាយតាមប្រទេសដូចម្តេច ? ដោយសារនរណា បានជាកម្ពុជាបានចូលជាសមាជិកអង្គការសហប្រជាជាតិ ? តើចូលពីថ្ងៃណា ? អំណាចគ្រប់គ្រងរដ្ឋសំខាន់ ៗ មានអ្វីខ្លះ ? កម្ពុជាកាន់លទ្ធិប្រជាធិបតេយ្យ ពីរជ្ជកាលក្សត្រអង្គណា ?

# វិធីបោះឆ្នោត

វិធីបោះឆ្នោត ជាការបញ្ចេញមតិផ្ទាល់របស់បណ្ដាជនគ្រប់ឋានៈ ក្នុងការជ្រើសរើសរកដំណាងខ្លួនឲ្យទៅកាន់មុខងារជាសមាជិករដ្ឋសភា ដើម្បីពិនិត្យកិច្ចការផែនដី ។

វិធីបោះឆ្នោតនេះ ដំបូងឡើងគេត្រូវបើកឱកាសឲ្យបេក្ខជនទាំងឡាយមានសិទ្ធិដើរឃោសនាពន្យល់ពស្ត្រ ពីគោលបំណង ទីនឹ ឧត្តមគតិរបស់ខ្លួន ។ តែពាក្យឃោសនា ត្រូវហាមផ្ដាច់មិនឲ្យប្រើពាក្យ បង្កាច់មួលឲ្យខូចប្រយោជន៍ជាតិឡើយ ។ ពេលសម្រាប់ឃោសនានេះ ហៅថា « សម័យបោះឆ្នោត » ។ ហើយត្រូវបិទសម័យនេះនៅពេលអគ្រាត្រមុនបោះឆ្នោត ១ ថ្ងៃ ។ លុះដល់ថ្ងៃកំណត់ទីនឹបោះឆ្នោត ត្រូវកំណត់ពេលពេញមួយថ្ងៃគត់ គឺចាប់ពីម៉ោង ៦ ព្រឹក រហូតម៉ោង ៦ ល្ងាច ។

ជនដែលមានសិទ្ធិបោះឆ្នោត ត្រូវនាំគ្នាទៅកាន់ការិយា-

ល័យបោះឆ្នោតដែលកងការបានកំណត់ឲ្យ ។ មេឃុំជាប្រធាន
នៃការិយាល័យទាំងនោះ ដោយមានអ្នកដំណាងបេក្ខជនទៅ
អង្គុយសង្កេតការជាមួយផង ។ អ្នកបោះឆ្នោត ត្រូវបង្ហាញ
ប័ណ្ណបោះឆ្នោតរបស់ខ្លួនទៅសមាជិកការិយាល័យ ដើម្បីទឹង
ចុះឈ្មោះបំណាំក្នុងបញ្ជី រួចទើបគេប្រគល់សន្លឹកឆ្នោតរបស់
បេក្ខជនម្នាក់ មួយសន្លឹក ៗ ។ បានសន្លឹកឆ្នោតហើយ អ្នក
បោះឆ្នោតត្រូវចូលទៅក្នុងបន្ទប់ជិតមួយ ជ្រើសរើសយកឆ្នោត
បេក្ខជនណាដែលខ្លួនត្រូវចិត្តបត់ជាបួន ហើយដើរចេញយក
ទៅទំលាក់ក្នុងហិបឆ្នោត ដែលដំកល់លើតុ ឯឆ្នោតឯទៀត
ក៏បត់ជាបួនដែរ តែត្រូវបោះចោលទៅក្នុងធុងមួយ ដែលដាក់
នៅក្រោមតុ ។ លុះដល់ម៉ោងហើយ ប្រធានការិយាល័យត្រូវ
បើកប់សន្លឹកឆ្នោតនៅចំពោះមុខសមាជិកទាំងអស់ ហើយត្រូវ
ធ្វើសេចក្ដីកត់ហេតុ ដោយមានចុះហត្ថលេខាសមាជិកការិយា-
ល័យផង រួចបញ្ជូនទៅសាលាស្រុកក្លាម ។ សាលាស្រុក
បន្តលិខិតនេះទៅសាលាខេត្ត ដែលសាលាខេត្តត្រូវបញ្ជូនបន្ត

ទៅឯក្រសួងមហាផ្ទៃ ។ បេក្ខជនណាដែលបានចំនួនសន្លឹកឆ្នោតច្រើនលើសគេចាប់ពីមួយសន្លឹកឡើងទៅ ត្រូវប្រកាសថាត្រូវបានទទួលការជ្រើសរើស ។ បើមានបេក្ខជនពីររូបបានទទួលសន្លឹកឆ្នោតច្រើនជាប់គេនោះ ត្រូវសន្មតយកបេក្ខជនណាមានអាយុច្រើនជាង ជាអ្នកជាប់ឆ្នោត ។

## សំណួរ

ការបោះឆ្នោតជាអ្វី ? មុនបោះឆ្នោតគេត្រូវធ្វើដូចម្ដេច ? ពេលនោះហៅថាសម័យអ្វី ? គេបោះឆ្នោតដោយប្រើវិធីដូចម្ដេច ? អ្នកណាជាប្រធានការិយាល័យបោះឆ្នោត ?

# រដ្ឋសភា

រដ្ឋសភាជាអង្គការ ជ្រើសតាំង ដែលបណ្ដាជនបានបញ្ចេញមតិទុកចិត្តដោយការបោះឆ្នោតសាកល គឺបណ្ដាជនក្នុងចំនួន ៣ ម៉ឺននាក់ ត្រូវចាត់ទុកជាមួយមណ្ឌល ជ្រើសរើសយកដំណាងម្នាក់ឲ្យទៅរួមប្រជុំធ្វើការក្នុងមន្ទីរមួយ ហៅថារដ្ឋសភា ។ ការបោះឆ្នោតនេះ ធ្វើដោយវិធីសម្ងាត់ គឺពលរដ្ឋទាំងពីរប្រភេទដែលមានអាយុចាប់តាំងពី២០ឆ្នាំឡើងទៅ អាចបោះឆ្នោតបានគ្រប់គ្នា វៀរលែងតែជនណាដែលច្បាប់ហាមឃាត់ ដោយប្រាសចាកសិទ្ធិពលរដ្ឋ ឬ ជាពលយោធា ។

រដ្ឋសភាជាអ្នកកាន់អំណាចនីតិបញ្ញត្តិ គឺជាអ្នកតែងច្បាប់សព្វសារពើ សម្រាប់ប្រទេសនិងពិនិត្យសព្វកិច្ចការរាជការគ្រប់ក្រសួង ដូចជាថវិកាជាតិជាដើម ។ ច្បាប់ទាំងឡាយដែលរដ្ឋ-សភាអនុមតិហើយទើបនឹងទុកជាការបាន លុះត្រាតែបានបញ្ជូនទៅស្នើឲ្យក្រុមប្រឹក្សាព្រះរាជាណាចក្រពិនិត្យសម្រេចផង ។

អ្នកដំណាងរាស្ត្រនីមួយៗ ត្រូវមានអាយុយ៉ាងតិច ២៥ ឆ្នាំ ពុំប្រកាន់ភេទ ឬ កំណត់កំរិតឋានៈ ឬ បំណេះវិជ្ជាឡើយ ឲ្យតែមានលក្ខណសម្បត្តិជាពលរដ្ឋពេញបរិបូណ៌ ។ កាលណាចូលរដ្ឋសភាហើយ អ្នកដំណាងរាស្ត្រត្រូវធ្វើការជាប្រយោជន៍ជាតិទូទៅ ពុំមែនធ្វើការសម្រាប់តែបណ្តាជនក្នុងមណ្ឌលដែលបោះឆ្នោតជ្រើសតាំងខ្លួនឡើយ ។ អង្គការនេះ ត្រូវធ្វើការក្រោមកិច្ចចាត់ចែងរបស់ក្រុមអភិបាលមួយ ដែលត្រូវជ្រើសតាំង ១ ឆ្នាំម្តង ។ ក្នុងចំណោមដំណាងរាស្ត្រជាសមាជិក ។

រដ្ឋសភាមានកំណត់នីតិកាល ៤ ឆ្នាំទើបផុតអំណាច ប៉ុន្តែប្រសិនជាមានហេតុភេទក្នុងប្រទេស មិនអាចធ្វើការបោះឆ្នោតជាថ្មីភ្លាម ៗ បានទេ ព្រះរាជាអាចបន្តអាណត្តិនៃរដ្ឋសភាចាស់បានម្តងមួយឆ្នាំ ។ អង្គការនេះ នឹងរលំមុនកំណត់ពេលបានទៅគ្រាណាដែលព្រះរាជាទ្រង់ប្រកាសរំលាយ ដោយអាស្រ័យសេចក្តីក្រាបបង្គំទូលណែនាំនៃគណៈរដ្ឋមន្ត្រី ។

*សរុបទៅ រដ្ឋសភាជាតំណាងប្រជាជាតិទាំងមូល ក្នុងការកសាង និង រក្សានូវកសនាប្រទេសជាតិ ។*

## សំនួរ

រដ្ឋសភាគឺជាអ្វី ? អ្នកណាជាសមាជិករដ្ឋសភា ? ជនប្រភេទណាខ្លះដែលមានសិទ្ធិបោះឆ្នោត ? មនុស្សបែបណាទើបធ្វើជាតំណាងរាស្ត្របាន ? មុខការរដ្ឋសភាធ្វើអ្វីខ្លះ ? រដ្ឋសភាមាននីតិកាលប៉ុន្មានឆ្នាំ? ក្នុងករណីណាទើបគេរំលាយរដ្ឋសភាបាន ?

# ក្រុមប្រឹក្សាព្រះរាជាណាចក្រ

ក្រុមប្រឹក្សាព្រះរាជាណាចក្រ ជាអង្គការជ្រើសតាំង តែដោយវិធីបោះឆ្នោតមិនទូទៅ គឺថាមានតែអ្នកមានអាជីវកម្មពិតប្រាកដទើបទៅបោះឆ្នោតបាន ។

អង្គការនេះ មាននាទីជាទីប្រឹក្សាទិងពិនិត្យសេចក្ដីព្រាងច្បាប់តាំងឡាយដែលរដ្ឋសភាបញ្ជូនមក ហើយដែលរដ្ឋសភាបានអនុម័តរួចម្ដងហើយ ។ ក្រោយដែលពិនិត្យទិងឲ្យយោបល់ស្រេចហើយ ក្រុមប្រឹក្សាព្រះរាជាណាចក្រត្រូវបញ្ជូនសេចក្ដីនេះ ទៅរដ្ឋសភាវិញ ក្នុងកំណត់ពេលមួយខែ, បើសិនជាការប្រញាប់កំណត់ពេលត្រឹមពីរថ្ងៃ ។

សមាជិកនៃក្រុមប្រឹក្សានេះ ត្រូវមានអាយុយ៉ាងតិចត្រឹម ៤០ ឆ្នាំ ដ្បិតគេត្រូវសំរាំងយកតែមនុស្សមានវ័យច្រើន ប្រកបដោយការពិសោធន៍គ្រប់គ្រាន់ក្នុងវិជ្ជាជីវៈនិមួយ ៗ ។ ក្រុមប្រឹក្សាព្រះរាជាណាចក្រ មានសមាជិក ២៤ រូប គឺពីររូបព្រះ

កជាទ្រង់ចាត់តាំង , ពីររូប រដ្ឋសភាជ្រើសតាំង ក្រៅពីអ្នកដំណាងក្រសួង , បួនរូប អ្នករាជការគ្រប់ដំណែងជ្រើសតាំង , ៨ រូបជាដំណាងភូមិភាគនានាក្នុងប្រទេស និង ៨ រូបទៀតជាដំណាងអ្នកមានវិជ្ជាជីវៈផ្សេង ៗ ។ ភូមិភាគទាំង ៨ នោះគឺ ៖ ១– ភ្នំពេញ, ២– កំពង់ចាម, ៣– កណ្ដាល, ៤– បាត់ដំបង និង សៀមរាប, ៥– កំពត និង តាកែវ, ៦– ព្រៃវែង និង ស្វាយរៀង, ៧– កំពង់ស្ពឺ, កំពង់ឆ្នាំង និង ពោធិសាត់, ៨– កំពង់ធំ, ក្រចេះ និង ស្ទឹងត្រែង ។

អង្គការនេះ មានកំណត់ទីកាល ៤ ឆ្នាំ ហើយត្រូវបើកប្រជុំស្មើគ្នានឹងរដ្ឋសភាដែរ ។ ចំណោមអ្នកបោះឆ្នោតរើសដំណាងនេះ ប្រសិនជាសង្កេតឃើញថា ដំណាងខ្លួនពុំពេញចិត្តដោយប្រព្រឹត្តខុស អាចធ្វើជាពាក្យថ្វាយចំពោះព្រះរាជាសុំបញ្ឈប់តំណាងរូបនោះបាន ប៉ុន្តែ ត្រូវមានចំនួនអ្នកសុំឲ្យមានភាគច្រើនដាច់ខាត ។ ហើយអាចជ្រើសរើសម្នាក់ទៀតមក

ជំនួសបាន ក្រោយដែលក្រុមប្រឹក្សានេះ ចាត់ឲ្យសមាជិកខ្លួនបួនរូបទៅធ្វើអង្កេតឃើញថាខុសពិតប្រាកដ ដូចពាក្យបណ្ដឹងហើយ ។

សរុបទៅ ក្រុមប្រឹក្សាព្រះរាជាណាចក្រ ជាអង្គការសំរាប់ពិនិត្យនឹងឲ្យយោបល់ចំពោះសេចក្ដីព្រាងច្បាប់ដែលរដ្ឋសភាស្នើមក ។

## សំនួរ

ក្រុមប្រឹក្សាព្រះរាជាណាចក្រជាអ្វី ? គេបោះឆ្នោតរើសក្រុមប្រឹក្សានេះដោយវិធីណា ? ក្រុមប្រឹក្សានេះមានសមាជិកប៉ុន្មានរូប ? ជាតំណាងអ្វីខ្លះ ? មានមុខងារធ្វើអ្វីខ្លះ ? ភូមិភាគទាំង ៨ គឺឯណាខ្លះ ?

# គណៈរដ្ឋមន្ត្រី

គណៈរដ្ឋមន្ត្រី ជារដ្ឋាភិបាលនៃព្រះមហាក្សត្រ មានសមាជិកយ៉ាងច្រើនត្រឹម ១៦ រូប រាប់ទាំងរដ្ឋលេខាធិការផង ។ សមាជិករដ្ឋសភា ឬ សមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រ អាចធ្វើជាសមាជិករដ្ឋាភិបាលផងក៏បាន ។ គណៈរដ្ឋមន្ត្រីនីមួយ ៗ ត្រូវមាននាយកម្នាក់ជាអ្នកណែនាំ ។ ព្រះរាជាទ្រង់ជាអ្នកចាត់តាំងវរជនមួយរូបឲ្យរៀបចំគណៈរដ្ឋមន្ត្រី គឺឲ្យវរជននោះរើសរកសហការីរបស់ខ្លួន ។ មុននឹងឡើងកាន់អំណាច គណៈរដ្ឋមន្ត្រីត្រូវទៅបង្ហាញខ្លួនចំពោះរដ្ឋសភា សុំឲ្យអង្គការនោះបញ្ចេញសេចក្តីទុកចិត្តលើខ្លួន នឹងចូលក្រាបបង្គំគាល់ព្រះរាជា ដើម្បីធ្វើសច្ចាប្រណិធានចំពោះរាជបល្លង្ក នឹងចំពោះជាតិ ។

គណៈរដ្ឋមន្ត្រី ជាអ្នកកាន់អំណាចនីតិប្រតិបត្តិ គឺជាអ្នកប្រើច្បាប់ដែលរដ្ឋសភាប្រកាសឲ្យប្រើ ។ ក្រៅពីនេះ គណៈរដ្ឋមន្ត្រីអាចព្រាងច្បាប់ដោយខ្លួនឯងបានដែរ តែត្រូវសុំសេចក្តីយល់ព្រមពីរដ្ឋសភា ដោយបញ្ជូនច្បាប់នោះទៅរដ្ឋសភាពិនិត្យ

សិន ។ ក្នុងករណីនេះ សមាជិកគណៈរដ្ឋមន្ត្រីអាចចូលទៅកាន់មន្ទីររដ្ឋសភាបាន ដើម្បីការពារច្បាប់ដែលខ្លួនព្រាង ។ រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការម្នាក់ ៗ ត្រូវទទួលខុសត្រូវរួមគ្នា ចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់គណៈរដ្ឋមន្ត្រីទាំងមូល ។ បើមានអ្នកដំណាងរាស្ត្រមួយនាក់ ឬច្រើននាក់ តាំងសំនួរដេញដោល អំពីការអនុវត្តិរបស់ខ្លួន រដ្ឋមន្ត្រីត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភាភ្លាម ។ កាលណារដ្ឋសភាបញ្ចេញមតិបន្ទោសឬមិនទុកចិត្ត គណៈរដ្ឋមន្ត្រីត្រូវលាលែងទាំងគណៈ។ ប្រសិនជារដ្ឋសភាបន្ទោសតែលើរដ្ឋមន្ត្រីមួយរូបនោះ ត្រូវដករូបរដ្ឋមន្ត្រីនោះចេញតែមួយរូបក៏បាន ។ តែបើនាយកជំទាស់មិនព្រមឲ្យដករូបរដ្ឋមន្ត្រីនេះទេ ត្រូវតែឲ្យរដ្ឋសភាបញ្ចេញសេចក្តីទុកចិត្តជាថ្មីម្តងទៀត ។

សមាជិកគណៈរដ្ឋមន្ត្រី នឹងទទួលទោសបានដោយសារការប្រព្រឹត្តខុសជាទម្ងន់ក្នុងមុខក្រសួងរបស់ខ្លួន ហើយដែលរដ្ឋសភាសម្រេចបញ្ជូនទៅតុលាការជាន់ខ្ពស់ ។

## សំនួរ

គណៈវត្តមន្ត្រីគឺជាអ្វី ? តើមានមុខងារធ្វើអ្វីខ្លះ ? ត្រូវមានសមាជិកប៉ុន្មានរូប ? នរណាជាអ្នកដឹកនាំគណៈវត្តមន្ត្រី ? មុននឹងឡើងកាន់អំណាចគណៈវត្តមន្ត្រីត្រូវធ្វើដូចម្តេច ? គេអាចចោទប្រកាន់ វត្តមន្ត្រីបាន ដោយអាស្រ័យករណីយ៉ាងណា ? បើសមាជិករដ្ឋសភាបង់ស្នូរដេញដោល វត្តមន្ត្រីត្រូវធ្វើដូចម្តេច ?

# មុខងារនៃគណៈរដ្ឋមន្ត្រី

រដ្ឋមន្ត្រីនិមួយៗសុទ្ធតែមានដំណែងទទួលខុសត្រូវចំពោះ មុខងារដោយឡែកៗពីគ្នាៗ ជួនកាលរដ្ឋមន្ត្រីមួយរូបកាន់ ផល់ទៅបី-បួនដំណែងក៏មាន ដោយមានរដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការជាជំនួយផងៗ ក្រៅពីដំណែងនាយកនិងឧបនាយកដែលជាអ្នកសម្រេចការលើគេបង្អស់, រដ្ឋមន្ត្រីនានា មានមុខងារដូចតទៅ ៖

១– ក្រសួងផែនការ ពិនិត្យនូវទំរង់ការកសាងជាតិ ដែលវិវត្តទៅតាមសេចក្ដីចំរើនគ្រប់ក្រសួងៗ

២– ក្រសួងអប់រំជាតិ ទទួលភារៈខាងផ្សាយចំណេះ និងអប់រំបណ្ដាជនទូទៅ និងកិច្ចការខាងវប្បធម៌ ៗ

៣– ក្រសួងកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាត់ចែងខាងការបង្កើនផលិតផលក្នុងប្រទេស ផ្នែកឧស្សាហកម្ម, ពាណិជ្ជកម្ម ។ល។ និង កាន់កាប់បញ្ជីប្រាក់ចំណូល-ចំណាយគ្រប់យ៉ាងរបស់ប្រទេស ៗ

៤- ក្រសួងការបរទេស ទទួលការៈទាក់ទងការទូតជាមួយបរទេស និងកិច្ចការខាងក្រៅប្រទេស ។

៥- ក្រសួងការពារប្រទេស ទទួលបន្ទុកខាងកងទ័ព គឺជាអ្នកការពារព្រំដែន និងបំបាំងកំងផល់ ។

៦- ក្រសួងសន្តិសុខជាតិ ជាអ្នករក្សាសេចក្តីសុខស្ងប់ រៀបរយក្នុងប្រទេស ។

៧- ក្រសួងសាធារណការ ចាត់ចែងខាងការស្ថាបនាអគារ និងសំណង់ផ្សេងៗ ជាសម្បត្តិសាធារណៈ ។

៨- ក្រសួងសុខាភិបាល ថែរក្សាជម្ងឺរោគា ឬការពារនិងជម្ងឺរបស់បណ្តាជនជាពលរដ្ឋ ។

៩- ក្រសួងឃោសនាការ ចាត់ចែងផ្សាយដំណឹងសព្វសារពើពីកផការឲ្យបណ្តាជនបានដឹងផង ។

១០- ក្រសួងកសិកម្ម ក៏ប់រងខាងការធ្វើចំការច្បារដំណាំក្នុងស្រុក និងការរក្សាធនធានរបស់ជាតិ មានការថែរក្សាព្រៃ, បឹងបួរ និងការចិញ្ចឹមសត្វជាដើម ។

១១- ក្រសួងការងារ-សង្គមកិច្ច ចាត់ចែងខាងការងាររបស់កម្មករ និងបញ្ហាសង្គមកិច្ចរបស់ជនរួមជាតិ ។

១២- ក្រសួងធម្មការ ទទួលភារៈខាងការពាក់ព័ន្ធផ្នែកសាសនា និងការសិក្សាខាងពុទ្ធសាសនា ។

១៣- ក្រសួងយុត្តិធម៌ មានភារៈខាងការជំនុំជំរះក្ដីឲ្យបណ្ដាជន តាមច្បាប់តុលាការ ។

១៤- ក្រសួងមហាផ្ទៃ ក៏ប់រងខាងកិច្ចការរដ្ឋបាល មានមន្ត្រីរក្សាឃុំ-ស្រុក-ខេត្ត ជាដើម ។

ជួនក្រសួងទាំងនេះមានបំបែកជាសាខា ទៅជាក្រសួងបន្ទាប់បន្សំផ្សេងទៀត ដោយយោលទៅតាមសេចក្ដីចំរើនរបស់ប្រទេស និងកាលទេសៈ ។

### សំនួរ

រដ្ឋមន្ត្រីម្នាក់ៗកាន់កាប់មុខដំណែងបែបណា ? ចូររាប់រៀបពីមុខងារនៃរដ្ឋមន្ត្រីតាមក្រសួងនិមួយៗ ។ ក្រសួងទាំងនេះអាចនឹងថែមថយទៀតបាន ឬទេ?

# អំពីតុលាការ

តុលាការ គឺជាក្រុមកងការមួយ ទទួលភារៈខាងការជំនុំជំរះក្ដីឲ្យបណ្ដាជនទូទៅជាពលរដ្ឋក្នុងប្រទេស ។ ហេតុដូច្នេះហើយ តុលាការត្រូវបែកអំណាចជាសាលាជំនុំជំរះក្ដីច្រើនជាន់ច្រើនថ្នាក់ដែលមាននាទីផ្សេងៗពីគ្នាដូចតទៅ ៖

១- សាលាលហុ .- សាលាលហុជំនុំជំរះក្ដីណាជាកំហុសស្រាល ៗ ដោយការប្រហែសធ្វេសនឹងច្បាប់ ដូចជាការទាស់ទែងដោយពាក្យសំដី, ការល្មើសនឹងបទបញ្ញារៀបចំទីកន្លែងរបស់កងការជាដើម ។ សាលានេះមានចៅក្រមម្នាក់ជាចាងហ្វាងជំរះក្ដី និងមានក្រឡាបញ្ជីមួយរូប ឬ ច្រើនរូបជួយធ្វើការផង ។ បទលហុបើត្រូវកាត់ទោសដាក់គុក គឺត្រូវជាប់ត្រឹមពី ១ថ្ងៃ ទៅ ៥ថ្ងៃ ដោយបើកផ្លូវឲ្យអ្នកត្រូវទោសសុំឧទ្ធរណ៍ ឬប្ដឹងសាទុក្ខទៅសាលាវិនិច្ឆ័យផង, បើពិន័យជាប្រាក់វិញ គឺត្រូវផាកពី ១៥ រៀល ទៅ ១៥០ រៀល ដោយមិនបើកផ្លូវឲ្យ

ឧទ្ធរណ៍ទេ ។ សព្វថ្ងៃគេបានបង្កើតសាលាលហុ នៅគ្រប់សាលាស្រុកក្នុងព្រះរាជាណាចក្រ ។

២– សាលាដំបូង .– សាលាដំបូងជំរះក្តីពិបាកជាងត្រឹមបទមជ្ឈិមប៉ុណ្ណោះ គឺពិន័យជាប្រាក់ពី ១៥១ រៀលរហូតដល់ ៤.០០០ រៀល ឬ ដាក់គុកពី ៦ ថ្ងៃទៅទល់ ៥ ឆ្នាំ ។ បើគូក្តីមិនសុខចិត្តតាមសេចក្តីសម្រេចរបស់សាលាដំបូងទេ អាចសុំតវ៉ាទៅសាលាជាន់ខ្ពស់ឯទៀតបាន ។ សាលានេះ ត្រូវមានចាងហ្វាង, ព្រះរាជអាជ្ញា, សុភាចារបុរស ក្រឡាបញ្ជីនិង សមុហបញ្ជីច្រើនរូបទៅរួមគ្នាធ្វើការ ។ សាលាដំបូងមានតាំងនៅគ្រប់ខេត្តទាំងអស់ក្នុងព្រះរាជាណាចក្រ ។

៣– សាលាឧទ្ធរណ៍ .– សាលាឧទ្ធរទទួលភារៈខាងការសើរើពិនិត្យសម្រេចសាជាថ្មី ចំពោះសំណុំរឿងទាំងឡាយណា ដែលគូក្តីបានប្តឹងតវ៉ាពុំព្រមតាមការវិនិច្ឆ័យ នៃសាលាលហុ ឬ សាលាដំបូង ឯបុគ្គលិក នៃសាលានេះក៏មាន

ចំនួនប្រហែលសាលាដំបូងដែរ ។ នៅប្រទេសកម្ពុជាយើងមានសាលាឧទ្ធរណ៍តែមួយនៅក្រុងភ្នំពេញ ហេតុនេះសំណុំរឿងទាំងឡាយដែលគេតវ៉ាមកសាលានេះ ក៏ត្រូវបញ្ជូនមកពីគ្រប់ខេត្តទាំងអស់ ។

## សំនួរ

តុលាការគឺជាអ្វី ? ដើម្បីឲ្យបានងាយក្នុងការពិនិត្យរឿងក្ដី តុលាការត្រូវធ្វើដូចម្ដេច ? សាលាលហុមាននាទីជំរះរឿងអ្វីខ្លះ ? សាលាដំបូងមានភារៈធ្វើអ្វីខ្លះ ? សាលាដំបូងមាននៅឯណាខ្លះ ? សាលាឧទ្ធរណ៍មានមុខងារធ្វើអ្វីខ្លះ ? មានសាលាឧទ្ធរណ៍ប៉ុន្មានក្នុងប្រទេសកម្ពុជា ?

# អំពីតុលាការ (ត)

៤– សាលាឧក្រិដ្ឋ .– សាលាឧក្រិដ្ឋជាសាលាជាន់ខ្ពស់ជំនុំជំរះពីបទឧក្រិដ្ឋ គឺកំហុសធំបំផុត ដែលត្រូវផ្តន្ទាទោសជាប់គុកពី ៥ ឆ្នាំ ទៅមួយជីវិត ឬប្រហារជីវិតបង់ក៏សឹងមាន ៗ ដូចេះ សាលានេះ មានមុខងារជាពិសេសតែក្នុងការកាត់ទោសធ្ងន់ ៗ ដូចបទឃាតកម្ម, ក្បត់ជាតិជាដើម ។

សាលាឧក្រិដ្ឋមានតែមួយទេ តាំងនៅក្រុងភ្នំពេញ ។ ប្រសិនជាគូក្តីមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលានេះ អាចប្តឹងត″ទៅសាលាវិនិច្ឆ័យឲ្យពិនិត្យ ជំនុំជំរះទៅចុងបំផុតទៀត ។

៥– សាលាវិនិច្ឆ័យ .– សាលាវិនិច្ឆ័យជាសាលាជាន់ខ្ពស់ខាងការជំរះក្តីនៅប្រទេសកម្ពុជា គឺមាននាទីត្រួតពិនិត្យនូវសេចក្តីសម្រេចរបស់សាលានានា ដែលបានកាត់សេចក្តីចេញសាលក្រមរួចហើយ ។ សាលានេះពុំបាច់ស៊ើបសួរដំណើរដើមឲ្យហូរហែដូចសាលាមុន ៗ ឡើយ គ្រាន់តែពិនិត្យការសម្រេចមុនឲ្យឃើញថាយុត្តិធម៌ពិតប្រាកដមែន ឬទេ ។

បានជាសើរើពិនិត្យម្តងទៀតនេះ ព្រោះគូក្តីបានប្តឹងសុំវិនិច្ឆ័យសាជាថ្មី ដ្បិតខ្លួនពុំអស់ចិត្ត នឹងការសម្រេចរបស់សាលាមុនៗ បើសាលាវិនិច្ឆ័យ ពិនិត្យទៅហើយឃើញថា ការសម្រេចមុនត្រឹមត្រូវហើយ ត្រូវបដិសេធពាក្យបណ្តឹងសាទុករបស់គូក្តីជាអសារបង់ ។ តែបើឃើញថា សាលាមុនៗ កាត់ក្តីនេះពុំត្រឹមត្រូវទេ ត្រូវជំនុំជំរះម្តងទៀត ។ ដូច្នេះ សាលាវិនិច្ឆ័យមានសុទ្ធតែចៅក្រមដែលមានវ័យចាស់ ប្រកបដោយការពិសោធន៍ច្រើន សំរាប់បញ្ជាក់រកយុត្តិធម៌ឲ្យគូក្តី ។

៦– តុលាការជាន់ខ្ពស់ .– ដើម្បីជំនុំជំរះក្តីនាទោសមន្ត្រីថ្នាក់ខ្ពស់បំផុត មានរដ្ឋមន្ត្រី, រដ្ឋលេខាធិការជាដើម រាជការបានបង្កើតអង្គការមួយទៀត ឲ្យមានសមត្ថភាពខ្ពស់ ហៅថា « តុលាការជាន់ខ្ពស់ » ។ តុលាការនេះ ជាអង្គការជ្រើសតាំងដែរ គឺផ្សំដោយសមាជិក ៥ រូប ជាចៅក្រមជាន់ខ្ពស់ពីររូប, សមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រ ពីររូប នឹងសមាជិករដ្ឋសភាមួយរូប ។

## សំនួរ

សាលាឧក្រិដ្ឋមានសមត្ថភាពដូចម្ដេចខ្លះ ? សាលានេះមានប៉ុន្មាននៅប្រទេសកម្ពុជា ? សាលាវិនិច្ឆ័យមាននាទីដូចម្ដេច ? ហេតុម្ដេចបានជាគេរើសចៅក្រមចាស់ ៗ ឲ្យធ្វើការនៅសាលាវិនិច្ឆ័យ ? ហេតុអ្វីបានជាគេបង្កើតតុលាការជាន់ខ្ពស់ ? នរណាខ្លះជាសមាជិកតុលាការជាន់ខ្ពស់ ?

# ព្រះមហាក្សត្រិយ៍

ព្រះមហាក្សត្រិយ៍ទ្រង់ជាអគ្គប្រមុខរដ្ឋ និង ជាទីគោរពសក្ការៈនៃខេមរជនទូទៅ នរណាមួយនឹងល្មើសលើព្រះអង្គពុំបានឡើយ ។ ទីតំណែងនៃព្រះអង្គ ត្រូវកំណត់តាំងពីព្រះជន្មាយុដប់ប្រាំបីវស្សាឡើងទៅ ។ ព្រះរាជាទ្រង់នូវព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទ ដើម្បីគ្រងរាជ្យជាដំណតពីព្រះអង្គ និង ព្រះរាជអំណាចដកហូតព្រះរជ្ជទាយាទពីដំណែងវិញបាន កាលណាព្រះអង្គទ្រង់ប្រជុំពិគ្រោះជាមួយក្រុមប្រឹក្សារាជសម្បត្តិរួចហើយ ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះរាជសិទ្ធិប្រស្រ័យជាមួយរដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជាណាចក្របានដោយព្រះរាជសាសន៍ ឬ ព្រះអង្គទ្រង់ត្រាស់បង្គាប់ឲ្យវរជនណាមួយចូលទៅកាន់មន្ទីរសភាទាំងនេះ ជាដំណាងព្រះអង្គបាន ដើម្បីថ្លែងយោបល់ ឬ ការសំខាន់ផ្សេង ៗ ។ ព្រះរាជាទ្រង់ជាអគ្គប្រមុខលើកងកម្លាំងទាំងឡាយ នៃព្រះរាជាណាចក្រ និង ទ្រង់នូវព្រះរាជសិទ្ធិបង្កើត ព្រមទាំងទ្រង់ព្រះរាជទាន

ហាននូវសក្តិខាងទាហាន និងស៊ីវិល ។ ក្រៅពីនេះព្រះអង្គទ្រង់នូវសិទ្ធិបន្ធូរទោស ឬលើកលែងទោសដល់មនុស្សជាប់ទោសដែលតុលាការសំរេចរួចហើយ ។

ក្នុងការជ្រើសតាំងគណៈរដ្ឋមន្ត្រី ព្រះរាជាទ្រង់នូវភារៈជាអ្នកជ្រើសតាំងវរជនមួយរូបឲ្យធ្វើជានាយករដ្ឋមន្ត្រី ព្រមទាំងរដ្ឋមន្ត្រីនានា ដែលនាយកនោះក្រាបបង្គំទូលសុំ ហើយព្រះអង្គទ្រង់នូវព្រះសិទ្ធិរំលាយរដ្ឋសភាបាន តាមសេចក្តីក្រាបបង្គំទូលស្នើនៃគណៈរដ្ឋមន្ត្រី ។

ចំពោះការតែងតាំង មន្ត្រីទូតឲ្យទាក់ទងទៅមកជាមួយបរទេសជាមិត្ត ក៏ជាភារៈរបស់ព្រះរាជាដែរ ។

កាលណាអង្គព្រះមហាក្សត្រស្តេចពុំគង់នៅក្នុងប្រទេស ឬពុំអាចទ្រង់ទទួលព្រះរាជភារៈបាន ព្រះអង្គទ្រង់ប្រគល់ព្រះភារៈទៅក្រុមប្រឹក្សាមួយសំរេចការជំនួសព្រះអង្គ ដោយតាំងឲ្យមានអធិបតី និង សមាជិក ក្នុងបណ្តាវរជនក្រៅពីសមាជិករដ្ឋាភិបាល ។

## សំនួរ

និតិភាពនៃព្រះមហាក្សត្រិយ៍កំណត់ត្រឹមព្រះជន្មាយុប៉ុន្មាន ? ដើម្បីតាំងព្រះរជ្ជទាយាទ តើព្រះរាជាទ្រង់ធ្វើដូចម្ដេច ? ព្រះអង្គប្រស្រ័យជាមួយសភាទាំងពីរដោយវិធីណាខ្លះ ? នរណាជាអ្នកផ្ដើមឲ្យឋានន្តរសក្ដិដល់មន្ត្រីស៊ីវិល និងទាហាន ? ដើម្បីចាត់នាយករដ្ឋមន្ត្រី ព្រះរាជាទ្រង់មានភារៈដូចម្ដេចខ្លះ ? ព្រះរាជាទ្រង់រំលាយរដ្ឋសភាបានដោយវិធីណា ?

# ក្រុមប្រឹក្សារាជសម្បត្តិ

រាជសម្បត្តិនៃប្រទេសកម្ពុជា ជាមរតករបស់ព្រះក្សត្រាទាំងឡាយ ដែលជាដំណពីព្រះបាទសម្តេចព្រះហរិរក្សរាមាធិបតីព្រះអង្គដួង ។ ដើម្បីថែរក្សារាជាធិបតេយ្យឲ្យបានល្អត្រឹមត្រូវ មានក្រុមប្រឹក្សាជាន់ខ្ពស់មួយសំរាប់ដោះស្រាយបញ្ហារាជបល្ល័ង្ក ហៅថាក្រុមប្រឹក្សារាជសម្បត្តិ ។ ឯការៈរបស់ក្រុមប្រឹក្សានេះមានដូចតទៅ ៖

កាលបើរាជសម្បត្តិទំនេរ ហើយប្រសិនជាព្រះរាជាអង្គមុនមិនបានតាំងរជ្ជទាយាទទេ នោះក្រុមប្រឹក្សារាជសម្បត្តិ ជាអ្នកតាំងព្រះរាជាអង្គថ្មី ដោយយកតាមភាគច្រើននៃទីប្រជុំ ។ បើមតិនេះមានភាគស្មើគ្នា ត្រូវសម្រេចយកតាមមតិប្រធាន ។ ការប្រជុំក្រុមប្រឹក្សាសំរាប់ករណីខាងលើនេះ ត្រូវធ្វើនៅក្នុងរវាងបីថ្ងៃក្រោយព្រឹត្តិការណ៍ដែលធ្វើឲ្យរាជសម្បត្តិទំនេរ ។ ប្រសិនបើព្រះរាជាអង្គថ្មី ទ្រង់នៅក្នុងអនីតិភាពនៅឡើយ ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវតាំងព្រះរាជា-

នុសិទ្ធមួយអង្គក្នុងចំណោមព្រះរាជវង្សានុវង្ស ដើម្បីចាត់ការជំនួសព្រះរាជា ។

ក្រុមប្រឹក្សារាជសម្បត្តិជាអ្នកវិនិច្ឆ័យ ថាព្រះមហាក្សត្រក្នុងរាជសម្បត្តិមានសមត្ថភាពឬទេ បើព្រះមហាក្សត្រគ្មានសមត្ថភាពទេ ក្រុមប្រឹក្សានេះត្រូវចាត់តាំងព្រះរាជានុសិទ្ធមួយអង្គឡើង ។

ការប្រជុំនៃក្រុមប្រឹក្សានេះ ត្រូវធ្វើដោយប្រធានអញ្ជើញ ឬបើប្រធានមិនបានអញ្ជើញទេ ត្រូវប្រជុំនៅថ្ងៃទី ៣ នៃរយៈវេលាដែលមានព្រឹត្តិការណ៍នាំឲ្យរាជសម្បត្តិទំនេរ ។

ក្រុមប្រឹក្សារាជសម្បត្តិមានសមាជិកដូចតទៅ ៖

— អធិបតីនៃក្រុមសង្គហព្រះរាជវង្សានុវង្សជាប្រធាន,
— ប្រធានរដ្ឋសភា ជាសមាជិក
— ប្រធានក្រុមប្រឹក្សាព្រះរាជាណាចក្រ ,,
— នាយករដ្ឋមន្ត្រី ,,
— ព្រះសង្ឃនាយកទាំងពីរគណៈ ,,
— ចាងហ្វាងតុលាការជាន់ខ្ពស់ ,,

## សំនួរ

រាជសម្បត្តិនៃប្រទេសកម្ពុជាមរតករបស់នរណា? ជាជំណរមកពីព្រះរាជាអង្គណា? បើរាជសម្បត្តិទំនេរ គេត្រូវធ្វើដូចម្តេច? ក្រុមប្រឹក្សារាជសម្បត្តិប្រជុំគ្នានៅពេលណា? បើវិនិច្ឆ័យទៅថាព្រះរាជានៅក្នុងអនីតិភាព តើក្រុមប្រឹក្សាត្រូវធ្វើដូចម្តេច? នរណាខ្លះជាសមាជិកក្រុមប្រឹក្សានេះ ?

# អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ ជាអង្គការអន្តរជាតិដែលជាតិនានា បានរួបរួមកម្លាំងគ្នារៀបចំបង្កើតឡើង ដើម្បីប្រមូលនូវគំនិតគ្នា សំរាប់សំរេចគោលបំណងដូចមានពណ៌នាខាងក្រោម ៖

– ថែរក្សាខ្ជាប់ខ្ជួននូវសន្តិភាពពិភពលោក គឺការពារកុំឲ្យប្រទេសមួយរុករានក្នុងប្រទេសមួយ ។

– បង្កើតការទាក់ទងរវាងប្រទេសនិងប្រទេស ឲ្យកាន់តែបានជិតស្និទ្ធឡើង ។

– ប្រមូលផ្តុំកម្លាំងគ្នា ហើយធ្វើសហប្រតិបត្តិការរកសេចក្តីចំរើនឲ្យពិភពលោក ។

– បង្កើតមន្ទីរមួយ សំរាប់ប្រជុំអ្នកដំណាងនៃប្រទេសទាំងឡាយជាសមាជិក ដើម្បីពិភាក្សាដោះស្រាយនូវបញ្ហាស្មុគស្មាញទាំងឡាយដែលពិភពលោកជួបប្រទះ ។

អង្គការនេះ បានបង្កើតច្បាប់មួយហៅថា « ធម្មនុញ្ញសហប្រជាជាតិ » សំរាប់ជាលក្ខខ័ណ្ឌក្នុងការអនុវត្តន៍តាមគោលបំណងរបស់ខ្លួន ។ ច្បាប់នេះបានទទួលការយល់ព្រមពីប្រទេសនានាដែលជាសមាជិក គឺមានដំណាងជនជាតិទាំងនោះចុះហត្ថលេខាយល់ស្របផង ។

កាលណាមានប្រទេសណាមួយ ទាស់ទែងខ្វែងគំនិតនឹងប្រទេសណាមួយទៀត បណ្តាលឲ្យខូចសេចក្តីស្ងប់រៀបរយក្នុងពិភពលោកនោះ អង្គការនេះត្រូវរកមធ្យោបាយគ្រប់បែបយ៉ាង សំរុះសំរួលឲ្យទាល់តែបានស្ងប់ស្រួលទៅវិញ ។ បើប្រទេសណាមួយ ជាសមាជិកពុំទាន់មានវឌ្ឍនធម៌បរិបូណ៌ខាងផ្នែកសេដ្ឋកិច្ចក្តី, វប្បធម៌ក្តី ឬសង្គមកិច្ចក្តី អង្គការនេះត្រូវមានវិធានការជួយដល់ប្រទេសនោះ ឲ្យទាល់តែបានចំរើនឡើង ។ ហេតុនេះហើយ បានជាអង្គការសហប្រជាជាតិបំបែកជាអង្គការរងច្រើនផ្នែកទៀត ដូចជាអង្គការអប់រំសុខ-

ភាព, អង្គការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌ និងអង្គការខាងចំណីអាហារជាដើម ។ មន្ទីរប្រជុំនៃអង្គការនេះ នៅក្រុងញូយ៉ក (សហរដ្ឋអាមេរិក) ។

ប្រទេសកម្ពុជាបានចូលជាសមាជិកនៃអង្គការសហប្រជាជាតិ ពីថ្ងៃទី ២០ ខែធ្នូ គ.ស ១៩៥៥ គឺដោយការដឹកនាំយ៉ាងប៉ិនប្រសប់នៃសម្តេចព្រះឧបយុវរាជ នរោត្តម-សីហនុ ជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមនៃជនជាតិខ្មែរ ។

## សំណួរ

ហេតុដូចម្តេចបានជាគេបង្កើតឲ្យមានអង្គការសហប្រជាជាតិ? អង្គការនេះមានបំណងដូចម្តេចខ្លះ ? អង្គការនេះមានអ្វីជាគោល ? គេមានបំបែកជាអង្គការ រងអ្វីខ្លះ ? មន្ទីរចាត់ការធំនៅឯណា ? កម្ពុជាបានចូលអង្គការនេះពីកាលណា ? ដោយសារនរណា ?

ចប់

# ដំណឹងពិសេស

សូមជូនដំណឹងដល់អស់លោក-អ្នក នាង កញ្ញា ជាសិក្ខា-កាមកុលបុត្រទាំងឡាយ

សូមជ្រាប ៗ

បណ្ណាគារ សេង-ង៉ួន ហួត តាំងនៅគេហដ្ឋានលេខ ៦៧ វិថីព្រះបាទ ចន្ទុកជា ភ្នំពេញ មានលក់សៀវភៅសិក្សាសំរាប់អ្នកសិក្សាគ្រប់ប្រភេទ នឹង មានប្រដាប់សំរាប់គ្រូ, សំរាប់សិស្សប្រដាប់ការិយាល័យគ្រប់យ៉ាង សូមអញ្ជើញចូលទាក់ទង !

ចំពោះអស់លោក ដែលត្រូវការយកទៅលក់ឯបណ្ណារនានា ដូចជានៅទីក្រុង នឹង ខេត្តក្រៅជាដើម សូមអញ្ជើញដោយមេត្រី នឹងមានលក់ដុំ នឹង លក់រាយជូន ដោយរីករាយ ៗ

សៀវភៅដែលបានផ្សាយចេញពី

# បណ្ណាគារ សេង-ងួន-ហ៊ួត

១- សរសេរតាមសូត្រពន្យល់ និពន្ធដោយ លី-ធាមតេង

២- អក្សរសាស្ត្រខ្មែរ -ដ-

៣- សារលិខិត -ដ-

៤- ប្រជុំអត្ថបទអក្សរសាស្ត្រ -ដ-

៥- ៣៥០ បំណោទ -ដ-

៦- តែងសេចក្ដីសម្រាប់ថ្នាក់ទី ៣ - ៤ ទំនើប -ដ-

៧- លោកនីតិ ដោយ គ្រូមួយក្រុម

៨- វេខាគណិតសាស្ត្រ ដោយ យូ-អ៊ាន

៩- វេយ្យាករណ៍ សម្រាប់ថ្នាក់ឧត្តមដ្ឋាន ឌុ. គាម

១០- សម្ពន្ធខ្មែរ ឌុ. គាម

១១- នវវេយ្យាករណ៍សម្រាប់ថ្នាក់ទី ៣ ទំនើប ព្រហ្មវិរៈ

១២- សិក្សាអត្ថបទ -ដ-

១៣- សម្ពន្ធវេយ្យាករណ៍ និង សម្ពន្ធមាលា -ដ-

| | |
|---|---|
| ១៤– អនុពាក្យទំនើប | ជា - ចន់ |
| ១៥– បឋមសិក្សាអង់គ្លេស–ខ្មែរ | កែន - ដួង |
| ១៦– សន្ទនាអង់គ្លេស–ខ្មែរ | ប៉ាន់ - ឌិត |
| ១៧– សន្ទនាខ្មែរ–រុស្ស៊ី | គ.អ. ប័ន្ធរិទ្ធ |
| ១៨– ច្បាប់ប្រុស | ច្បាប់បុរាណ |
| ១៩– ច្បាប់ស្រី | –ដ– |
| ២០– ច្បាប់បណ្តាំឪពុក | –ដ– |
| ២១– ច្បាប់ហៃមហាជន | –ដ– |
| ២២– ច្បាប់កូនចៅលៀក | –ដ– |
| ២៣– ច្បាប់ត្រីនេតិ | –ដ– |
| ២៤– ច្បាប់ពាក្យចាស់ | –ដ– |
| ២៥– ច្បាប់កេរ្តិ៍កាល | –ដ– |
| ២៦– រឿងហង្សយន្ត | សាស្ត្រាបុរាណ |
| ២៧– រឿងស័ង្ខសិល្បជ័យ ភាគ ១–២ | –ដ– |
| ២៨– រឿងក្រុងសុភមិត្ត | –ដ– |

២៩– រឿងនាងកង្រី  សាស្ត្រាបុរាណ

៣០– រឿងចៅស្រទបចេក ភាគ ១-២  –ដ–

៣១– រឿងសព្វសិទ្ធិ  –ដ–

៣២– រឿងទុំទាវ  –ដ–

៣៣– រឿងគាគី  –ដ–

៣៤– រឿងធនញ្ជ័យ  –ដ–

៣៥– រឿងពស់កេងកង  –ដ–

៣៦– រឿងមាយាស្រី  –ដ–



សួស្តី !

អស់លោក-អ្នក នាងកញ្ញា ដែលត្រូវការសៀវភៅច្បាប់សិក្សា ខ្មែរ, បារាំង, អង់គ្លេស ឬសៀវភៅរឿងព្រេងបុរាណ, រឿងប្រលោមលោក សម្រាប់ទស្សនាកំសាន្ត, ដែលជាស្នាដៃនៃអ្នកនិពន្ធដ៏មានឈ្មោះល្បីក្នុងប្រទេស សូមអញ្ជើញៗ ! បណ្ណាគារសេង-ង៉ួន ហ៊ួត នឹងរង់ចាំទទួលលោក-អ្នក នាងកញ្ញា ដោយរីករាយ !!

សួស្ដី ! ដំណឹងចុងក្រោយបំផុត ! រោងពុម្ព ៗ

អស់លោក-អ្នក ដែលត្រូវការបោះពុម្ពសៀវភៅ នឹង សំបុត្រអាពាហ៍ពិពាហ៍ ឬលិខិតផ្សេងៗសូមអញ្ជើញចូលទាក់ទងដោយមេត្រីភាព    រោងពុម្ព សេង-ងួន ហ៊ួត    តាំងនៅគេហដ្ឋានលេខ ៦៧ វិថីព្រះបាទចន្ទរាជា ភ្នំពេញ នឹងមានអ្នកជំនាញការ រង់ចាំទទួលលោក-អ្នករាល់ពេល សូមអញ្ជើញៗ ធ្វើការស្អាត ហើយរួសរាន់ទាន់ចិត្តផង

សួស្ដី ! រោងពុម្ព បណ្ណាគារ !

រោងពុម្ព បណ្ណាគារ សេង-ងួន-ហួរ

លេខ ៦៧ វិថីព្រះបាទបទុមភក្ដា

ភ្នំពេញ

តម្លៃ ១៥រ០០